# របាយការណ៍សង្ខេបស្តីពី
# ការសង្កេតលើការអនុវត្តកម្មវិធីនយោបាយ
# របស់រាជរដ្ឋាភិបាលអាណត្តិទី៣

ឆ្នាំទី១ ខែកក្កដា ឆ្នាំ២០០៤ - ខែធ្នូ ឆ្នាំ២០០៥ និង

សង្ខេបខ្លឹមសារឆ្នាំទី២ ស្តីពីលទ្ធផលគិតមកដល់ខែកក្កដា ឆ្នាំ២០០៦

# មាតិកា


**បុព្វកថា**........................................................................................................................១

**សង្ខេបខ្លឹមសារឆ្នាំទី ២**..............................................................................................២

**របាយការណ៍សង្ខេបឆ្នាំទី ១** ........................................................................................ ៤

**I-** **វិស័យនយោបាយ**.......................................................................................................៦

**II-** **វិស័យសេដ្ឋកិច្ច** ...................................................................................................... ១០

**III-** **ផ្នែកសង្គមកិច្ច** ........................................................................................................១៣

**IV-** **ការវិភាគ និងសេចក្តីសន្និដ្ឋាន** ...................................................................... ១៦

**វិធីសាស្ត្រ** ......................................................................................................................២០

# បុព្វកថា

នៅមុនការបង្កើតរាជរដ្ឋាភិបាលនីតិកាលទី៣នៃរដ្ឋសភានេះ គណបក្សជាប់ឆ្នោតទាំងបី (គណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី) បានចំណាយពេលជាងមួយឆ្នាំ ដើម្បីជជែកពិភាក្សាអំពីការរៀបចំកម្មវិធីនយោបាយមួយដ៏ល្អ ដែលស្រង់យកចេញមកពីការសន្យារបស់ខ្លួនអំឡុងពេលឃោសនាបោះឆ្នោត (ខែកក្កដា ឆ្នាំ២០០៣)។ ដោយសារហេតុផលនេះហើយ ទើបបានជាខុមហ្វ្រែលសំរេចធ្វើការអង្កេតលើការអនុវត្តកម្មវិធីនយោបាយទាំង៧៣ ចំណុចដែលបានព្រមព្រៀងគ្នាជាជាងធ្វើការតាមដានការសន្យារបស់គណបក្សនយោបាយនីមួយៗ ។

ដើម្បីសំរេចទិសដៅរបស់ខ្លួន ផ្នែកអង្កេត **ខុមហ្វ្រែល** ដែលគ្រប់គ្រងដោយ លោក **ម៉ារ សុផល** (អ្នកសម្របសម្រួលកម្មវិធីអង្កេតការណ៍) បានអនុវត្តសកម្មភាពអង្កេតការណ៍នានា ទាក់ទងទៅនឹងការបំពេញភារកិច្ចរបស់មន្ត្រីជាប់ឆ្នោតនៅក្នុងកំឡុងពេលក្រោយ និងចន្លោះការបោះឆ្នោតនិមួយៗ។ សកម្មភាពទាំងនោះរួមមាន ការអង្កេតលើការអនុវត្តការងាររបស់សមាជិករដ្ឋសភា ***"ឃ្លាំមើលសភា"*** និងការអង្កេតលើការងារអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល អាចហៅថា ***"ឃ្លាំមើលរដ្ឋាភិបាល"***។

ទិសដៅនៃសកម្មភាពអង្កេតការណ៍ទាំងនេះ គឺដើម្បីបង្កើនតម្លាភាពនៅក្នុងការអនុវត្តការងាររបស់មន្ត្រីជាប់ឆ្នោតទាំងឡាយ ។

សូចនាករនានា ដែលបានដកស្រង់ចេញពីកម្មវិធីនយោបាយ ត្រូវបានចងក្រងឡើងដោយទីប្រឹក្សាជំនាញមួយចំនួនរួមមាន លោក **ចន វីជីន** និងលោកស្រី **ព្រំ ធេវី**។ អរគុណជាអនេកចំពោះអ្នកទាំងពីរសំរាប់ការចូលរួមចំណែកដ៏មានតម្លៃនេះ។ ទិន្នន័យបន្ទាប់បន្សំ ត្រូវបានប្រមូលមកពីស្ថាប័នពាក់ព័ន្ធនានា រួមមានដូចជា ក្រសួងនានារបស់រាជរដ្ឋាភិបាល ធនាគារអន្តរជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប្រភពអេឡិចត្រូនិចនានា អ្នកជំនាញការឯករាជ្យ និងទីប្រឹក្សាជាច្រើន។ មតិយោបល់នានាត្រូវបានប្រមូលតាមរយៈបទសម្ភាសន៍ ។

ការវិភាគមួយចំនុចម្តងៗ ត្រូវបានធ្វើឡើងជាដំបូងជាភាសាខ្មែរ។ ទិន្នន័យខ្លះ មានតែជាភាសាអង់គ្លេស ដែលអាចបណ្តាលឱ្យមានការប្រែសម្រួលមិនបានត្រឹមត្រូវខ្លះពីភាសាខ្មែរទៅអង់គ្លេស និងច្រាសមកវិញ។ យើងបានខិតខំព្យាយាមកែតម្រូវ បញ្ហានេះ។

លោកស្រី **រ៉ូ ប្រ៊ិនហ្វីត្ស** និងលោក **ចន ឡូរី** បានជួយក្នុងការចងក្រងរបាយការណ៍នេះ។ អរគុណអ្នកទាំងពីរសំរាប់ការខិតខំជួយយ៉ាងអស់ពីកម្លាំងកាយចិត្ត។

សូមថ្លែងអំណរគុណជាពិសេសជូនចំពោះគណៈកម្មាធិការនាយកខុមហ្វ្រែល សំរាប់ការចំណាយពេលវេលា ក្នុងការផ្តល់នូវការលើកទឹកចិត្ត និងការគាំទ្រយ៉ាងពេញលេញ។ ព្រមជាមួយនឹងការអរគុណផងដែរចំពោះបុគ្គលិក**ខុមហ្វ្រែល** ដែលបានចូលរួមក្នុងការបំពេញការងារនេះ។

ជាទីបញ្ចប់នេះ ខុមហ្វ្រែល ក៏សូមសំដែងនូវអំណរគុណចំពោះម្ចាស់ជំនួយនានា មានដូចជា ណូវីប (NOVIB), ត្រូកែរហ្វាន់ (Trocaire Fund), អិន ភី អេ (NPA), អុកហ្វ្សាមហុងកុង (Oxfam HK), និងហ្វ័រ៉ុមស៊ីដ (Forum Syd), ចំពោះការផ្តល់នូវហិរញ្ញវត្ថុសំរាប់ផលិតរបាយការណ៍នេះ។ ឯកសារដែលបានបោះពុម្ពនេះជាការរួមបញ្ចូលរបាយការណ៍សង្ខេបទាំងឆ្នាំទី១ (ពី ខែកក្កដា ឆ្នាំ២០០៤ ដល់ ខែធ្នូ ឆ្នាំ២០០៥) និងសេចក្តីសង្ខេបខ្លឹមសារឆ្នាំទី២ ដែលផ្តោតតែទៅលើលទ្ធផលជាសូចនាករច្បាស់លាស់ (គិតមកដល់ខែកក្កដា ឆ្នាំ២០០៦) ។

សំរាប់របាយការណ៍លំអិតសូមទំនាក់ទំនងមកខុមហ្វ្រែល តាមរយៈអាសយដ្ឋានដូចមានដាក់នៅខាងក្រោយ ឬអាចបើកគេហទំព័រ www.comfrel.org ។ របាយការណ៍ទាំងនេះ មិនឆ្លុះបញ្ចាំងពីគោលបំណង និងទស្សនៈម្ចាស់ជំនួយទេ ។

**គល់ បញ្ញា**
**នាយកប្រតិបត្តិខុមហ្វ្រែល**

## សង្ខេបខ្លឹមសារឆ្នាំទី២ ស្តីពី
## លទ្ធផលជាសូចនាករច្បាស់លាស់នៃការអនុវត្តកម្មវិធីនយោបាយ
## របស់រាជរដ្ឋាភិបាលកម្ពុជា និងសកម្មភាពរបស់សភា និងតំណាងរាស្ត្រ
## អាណត្តិទី៣ គិតមកដល់ខែកក្កដា ឆ្នាំ២០០៦

ការសង្កេតនេះ បានយកចិត្តទុកដាក់ទៅលើលទ្ធផលមានសូចនាករច្បាស់លាស់ នៃការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ លទ្ធផលមានសូចនាករច្បាស់លាស់ក្នុងកម្មវិធីនយោបាយនោះ និយាយទៅដល់លទ្ធផលដែលអាចវាស់បាន និងការធ្វើសកម្មភាព ឬការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានពេលវេលា ឬ/និងមានចំនួនកំនត់ច្បាស់លាស់ ឧទាហរណ៍ដូចជាការរៀបចំអនុម័តច្បាប់អ្វីមួយ ឬ/និងការបង្កើតស្ថាប័នអ្វីមួយ ឬ/និងការបន្ថយ ឬការបង្កើនចំនួនសកម្មភាពដល់កំរិតណាមួយ ។

**មកដល់ខែ កក្កដា ឆ្នាំ ២០០៦នេះ ការសង្កេតរបស់ ខុមហ្វ្រែល រកឃើញថា លទ្ធផលមានសូចនាករ ច្បាស់លាស់ នៃការសន្យាក្នុងកម្មវិធីនយោបាយបានអនុវត្ត ៣០% (ក្នុងនោះ ១០%បានសំរេចក្នុងឆ្នាំទីពីរនេះ ពី ខែកក្កដា ឆ្នាំ២០០៥ ដល់ខែកក្កដា ឆ្នាំ២០០៦) ប៉ុន្តែ ៧០% មិនទាន់អនុវត្ត ឬបានអនុវត្តតែមិនទាន់ពេញលេញ (បានតិចតួច) ។**

ចំពោះការសន្យាក្នុងវិស័យនយោបាយ រាជរដ្ឋាភិបាល និងសភា បានខិតខំលើកស្ទួយសភាពការណ៍ (អាក្រក់ សេរីភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យខ្លះៗ ដែលបានធ្លាក់ចុះយ៉ាងខ្លាំង) នៅដើមខែនៃឆ្នាំទីពីរនេះ ។

នៅឆ្នាំទី២ នៃអាណត្តិទី៣នេះ មានការបំពេញបន្ថែមបានចំណុចសំខាន់ពីរទៀតគឺ *ការរៀបចំ និងអនុម័តសេចក្តីណែនាំស្តីពីការរៀបចំប្រធាន អនុប្រធាន និងសមាជិកភូមិដោយរាជរដ្ឋាភិបាលក្នុងខែមីនា ឆ្នាំ២០០៦ និងក្រមស្តីពីនីតិវិធីរដ្ឋប្បវេណីដែលត្រូវបានរដ្ឋសភាអនុម័តនាខែឧសភា ឆ្នាំ២០០៦* ។ មានការសន្យាចំនួនបួនក្នុងចំណោមការសន្យាចំនួនប្រាំមួយដែលរាជរដ្ឋាភិបាលនៅតែមិនទាន់បានបំពេញក្នុងលក្ខខណ្ឌឱ្យបានមុនដំណាច់ឆ្នាំ២០០៥ ។ ចំណុចសន្យាសំខាន់ៗដែលរាជរដ្ឋាភិបាលនៅមិនទាន់បានបំពេញរួមមាន ការអនុម័ត*ច្បាប់ស្តីពីបាតុកម្ម និងកូដកម្ម ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ច្បាប់ប្រឆាំងអំពើពុករលួយ និងមិនទាន់បង្កើតស្ថាប័នឯករាជ្យ អញ្ញាក្រឹត្យ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (បើទោះបីមានការសន្យាជាថ្មីថារៀបចំឱ្យបាននៅចុងខែមិថុនា ឆ្នាំ២០០៦ នេះក៏ដោយ)* ព្រមទាំងច្បាប់សំខាន់ៗសំរាប់ជំរុញកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងការគាំទ្រលទ្ធិប្រជាធិបតេយ្យ តួនាទីមតិប្រឆាំង(ជំទាស់)និងការអភិវឌ្ឍស្ថាប័ន មិនទាន់ត្រូវបានអនុម័តនៅឡើយ ។ ច្បាប់ទាំងឡាយដែលមិនទាន់មានការអនុម័តតាមការសន្យាក្នុងកម្មវិធីនយោបាយរួមមានដូចជា *ច្បាប់ លក្ខន្តិកៈចៅក្រម ក្រមព្រហ្មទ័ណ្ឌ នីតិវិធីព្រហ្មទ័ណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសារការី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អាជ្ញាសាលា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសមាជជាតិ និងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ* ។

***ស្ថាប័នជាតិសំខាន់ៗ*** ដែលបានលើកឡើងនៅក្នុងកម្មវិធីនយោបាយ ថានឹងបង្កើតនោះ ***នៅពុំទាន់លេចចេញជារូបរាងទេ*** តួយ៉ាងដូចជា ***គណៈកម្មាធិការជាតិសិទ្ធិមនុស្ស*** និងតុលាការឯកទេសមួយចំនួនរួមមានជាអាទិ៍ ***តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល*** ។ បើទោះបីមានការរំលាយចោលវិញ នូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែនក៏ដោយ ក៏រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ហើយបានបន្តជំរុញការចុះ ហត្ថលេខាលើកិច្ចព្រមព្រៀងព្រំដែន ។

***រាជរដ្ឋាភិបាលបានអនុវត្តពេញលេញ នូវការតម្លើងបៀវត្សរ៍ជូនមន្ត្រីរាជការទូទៅពី ១០% ទៅ ១៥% ក្នុងឆ្នាំទីពីរ*** ។ ប៉ុន្តែការតម្លើងនេះ ពុំបានជួយសម្រួលដល់ជីវភាពទេ ដោយសារតែស្ថានភាពតម្លៃទំនិញឡើងថ្លៃ ដែលជាហេតុបណ្តាលឱ្យការផ្តល់សេវាសាធារណៈនៅពុំទាន់មានប្រសិទ្ធភាព ។

**ចំណែកឯកំណែទម្រង់ដីធ្លីដែលជាបញ្ហាដ៏ក្តៅគគុកនោះ រាជរដ្ឋាភិបាលបានអនុវត្តតែមិនទាន់ពេញលេញ (បានតិចតួច)**

**ក្នុងការពិនិត្យឡើងវិញ នូវដីទំនេររបស់រដ្ឋ ឬដីរដ្ឋដែលឯកជនកាន់កាប់ និងការចេញប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី** ពិសេសគ្រួសារក្រីក្រ និងក្រុមជនងាយរងគ្រោះ និង *"មិនទាន់"* **បែងចែកដីធ្លីក្នុងក្របខណ្ឌដីសម្បទានដើម្បីគោលដៅសង្គមកិច្ចនៅឡើយ ។** របាយការណ៍អង្គការសិទ្ធិមនុស្ស និងផ្នែកច្បាប់មួយចំនួនរកឃើញថា នៅតែមានការបន្តទន្រ្ទានដីទំនេររបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិពីសំណាក់អ្នកមានអំណាច និងប្រាក់ បើទោះបីជាមានការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លីក៏ដោយ ។

ការសង្កេតសភា និងតំណាងរាស្ត្ររកឃើញថា ចំនួនសកម្មភាពអ្នកតំណាងរាស្ត្រចុះបេសកកម្មទៅកាន់មណ្ឌលនានា និងការឡើងបញ្ចេញមតិ និងសកម្មភាពផ្សេងៗទៀតរបស់អ្នកតំណាងរាស្ត្រនៅក្នុងមន្ទីររដ្ឋសភា មានការកើនឡើងធៀបឆ្នាំទីមួយ ។ ដូចឆ្នាំទីមួយនៃអាណត្តិទីបី របស់រាជរដ្ឋាភិបាលនេះ ***ប្រសិទ្ធភាពនៃការអនុវត្តសិទ្ធិ និងអំណាចរបស់សភា និងតំណាងរាស្ត្រនៅមានកម្រិត*** ជាពិសេសទាក់ទិនទៅនឹងអំណាចត្រួតពិនិត្យ និងតុល្យភាពអំណាចរបស់រដ្ឋសភា ទៅលើការបំពេញភារកិច្ចរបស់រាជរដ្ឋាភិបាល ។ មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបន្ថយចំនួនកូរ៉ុម សំរាប់ការបោះឆ្នោតសំដែងការទុកចិត្តរាជរដ្ឋភិបាល និងការអនុម័តច្បាប់ ពីសំលេងភាគច្រើនលើសលប់ពីរភាគបីមកជាសំលេងភាគច្រើនដាច់ខាត ៥០% + ១ សំលេង និងការផ្តល់ឱ្យសមាជិកសភានៃគណបក្សជំទាស់ ចូលក្នុងរចនាសម្ព័ន្ធដឹកនាំរបស់សភារួមមាន ប្រធានគណៈកម្មាការជំនាញចំនួនពីរ ។ ការសង្កេតរកឃើញថា សមាជិករាជរដ្ឋាភិបាល**មិនទាន់មានភាពសកម្ម** ក្នុងការមក **ឆ្លើយឆ្លងជាមួយតំណាងរាស្ត្រ** ព្រោះ តាមការសង្កេតទើបតែមានការចូលមកឆ្លើយសំនួរសមាជិកសភានៅក្នុងសម័យប្រជុំពេញអង្គបានតែ**២**លើកប៉ុណ្ណោះក្នុងចំណោមសំណើយ៉ាងហោចណាស់ **១២**លើករបស់អ្នកតំណាងរាស្ត្រ ។

*រាជរដ្ឋាភិបាលបានបំពេញនូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់រហូតដល់ជាង៧%* **បានរៀបចំកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈដូចការសន្យា និងបានអនុម័តការតម្លើងថវិកាជាតិឆ្នាំ ២០០៦ ប្រមាណ ២០%។** ទោះបីយ៉ាងណាក៏ដោយ នៅតែមានការ*ខ្វះខាតប្រសិទ្ធភាពក្នុងការអនុវត្ត និងការធានាឱ្យមានសមធម៌ ក្នុងការបែងចែកផ្លែផ្កាពីកំណើនសេដ្ឋកិច្ចនេះទៅដល់វិស័យនានា* ដូចជា វិស័យសង្គមកិច្ច សុខាភិបាល និងអប់រំ ដែលត្រូវបានចាត់ទុកជាវិស័យគន្លឹះសំរាប់ចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ ។ ការសិក្សាក្នុងឆ្នាំ២០០៦ថ្មីៗនេះរបស់ធនាគារពិភពលោកបានរកឃើញថា កម្ពុជាកើនឡើងនូវគំលាតមិនមានសមភាពរវាងអ្នកមាន និងអ្នកក្រ ក៏រិត ០.៤២ (បើនៅត្រឹមសូន្យ មានសមភាពល្អ ផ្ទុយទៅវិញបើស្មើ ១ គឺមិនមានសមភាពទាល់តែសោះ) ។ ***តម្លៃទំនិញសំខាន់ៗ*** ចាំបាច់សម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ***ដែលចេះតែបន្តកើនឡើង*** ជាពិសេស **ប្រេងឥន្ធនៈ ទំនិញ និងស្បៀងអាហារ ។** ការអនុវត្តកំណែទម្រង់ហិរញ្ញវត្ថុមានការយឺតយ៉ាវ ។ **មានច្បាប់ចំនួនពីរក៏នៅពុំទាន់ត្រូវបានអនុម័តក្នុងនោះរួមមាន** *ច្បាប់គ្រប់គ្រងកាស៊ីណូ និងច្បាប់ស្តីពីតំបន់ឧស្សាហកម្ម ។*

ដោយសារការអនុវត្តនៃការកែទម្រង់នៃវិស័យនយោបាយនៅយឺតយ៉ាវខ្លាំង និងការបែងចែកផ្លែផ្កានៃកំណើតនសេដ្ឋកិច្ចមិនបានល្អ (វិសមភាពយ៉ាងខ្លាំង) នាំឱ្យការអនុវត្តនៃវិស័យសង្គមកិច្ច អប់រំ និងសុខាភិបាលមិនបានបំពេញឱ្យបានល្អដដែល បើប្រៀបធៀបនឹងឆ្នាំទី១ ។

# របាយការណ៍សង្ខេបឆ្នាំទី១
# ស្តីពី
# ការសង្កេតលើការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៣
# កក្កដា ២០០៤ – ធ្នូ ២០០៥

របាយការណ៍នេះគ្របដណ្តប់រយៈពេល ១៨ខែ ចាប់ផ្តើមពី ខែកក្កដា ឆ្នាំ២០០៤ (ថ្ងៃបង្កើតរាជរដ្ឋាភិបាល) រហូតដល់ដំណាច់ ឆ្នាំ២០០៥។ របាយការណ៍នេះមានឈ្មោះថា **របាយការណ៍ឆ្នាំទី ១ ស្តីពីការសង្កេតការអនុវត្តកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាលអាណត្តិទី៣**។ របាយការណ៍នេះគ្របដណ្តប់រយៈពេលសង្កេតការណ៍ខាងលើ ដោយយោងលើមូលហេតុដូចតទៅ :

- ចាប់តាំងពីការបង្កើតរាជរដ្ឋាភិបាលនាខែកក្កដា ឆ្នាំ២០០៤ រហូតដល់ ខែធ្នូ ឆ្នាំ២០០៤ ដោយយោងតាមកិច្ចព្រមព្រៀង រវាងគណបក្សកាន់អំណាចទាំងពីរ រាជរដ្ឋាភិបាលស្ថិតនៅក្នុងដំណាក់កាលរៀបចំរចនាសម្ព័ន្ធថ្មីរបស់ខ្លួន។ ដូច្នេះជាលទ្ធផលក្នុងកំឡុងពេលនេះ មានការសំរេចបានសមិទ្ធផលតិចតួចប៉ុណ្ណោះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខុមហ្វ្រែល ក៏ធ្លាប់បានចេញផ្សាយរបាយការណ៍សង្កេត៦ ខែដំបូង របស់ខ្លួនស្តីពីការសង្កេតលើការអនុវត្តកម្មវិធីនយោបាយដោយផ្តោតលើវិស័យសំខាន់ៗមួយចំនួន។
- តាមពិតរបាយការណ៍រយៈពេលមួយឆ្នាំគឺត្រូវគិតពី ខែកក្កដា ២០០៤ រហូតដល់ខែកក្កដា ២០០៥ ប៉ុន្តែ ដោយសារមានការលំបាកជាច្រើន ក្នុងការប្រមូលទិន្នន័យពីស្ថាប័នពាក់ព័ន្ធនានា នៅពាក់កណ្តាលឆ្នាំ ជាមូលហេតុធ្វើឱ្យរបាយការណ៍នេះត្រូវបានពន្យាររហូតមកដល់ខែធ្នូ ២០០៥។

នៅក្នុងរបាយការណ៍នេះ គណៈកម្មាធិការខុមហ្វ្រែល បានខិតខំប្រឹងប្រែងផ្តល់នូវការវិភាគមួយផ្នែកម្តងៗ នូវវឌ្ឍនភាពនៃការអនុវត្ត ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះអ្នកបោះឆ្នោតនៅក្នុងអាណត្តិនេះ ដោយរួមបញ្ចូលទាំងការវាយតម្លៃដោយក្រសួងនានា និងដោយស្ថាប័នដ៏ទៃទៀត ដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងការងាររបស់ក្រសួង ជាពិសេសទីភ្នាក់ងារអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល។ សំរាប់របាយការណ៍នេះ ការវាយតម្លៃច្រើនផ្អែកលើអ្នកសង្កេតការណ៍ និងអ្នកជំនាញការឯករាជនានា នៅពេលអនាគត ខុមហ្វ្រែលនឹងដាក់បញ្ចូលនូវការវាយតម្លៃដោយអ្នកបោះឆ្នោតចំពោះបំពេញការងាររបស់រាជរដ្ឋាភិបាល។

យោងតាមការបង្ហាញនៃរបាយការណ៍នេះខុមហ្វ្រែលបានរកឃើញដូចខាងក្រោម:

**គណៈកម្មាធិការខុមហ្វ្រែល** សូមធ្វើការកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៣ សម្រាប់កិច្ចប្រឹងប្រែងក្នុងការរៀបចំឱ្យមានកម្មវិធីនយោបាយ៧៣ចំណុចនេះឡើង ជាមួយនឹងសូចនាករច្បាស់លាស់ជាច្រើនរបស់ខ្លួន។ លើសពីនេះទៀត រាជរដ្ឋាភិបាលក៏បានបង្ហាញពីសុឆន្ទៈរបស់ខ្លួននៅក្នុងគោលនយោបាយជាតិ *"យុទ្ធសាស្ត្រចតុកោណ"* ដែលមានការប្តេជ្ញាចិត្តសម្រេចឱ្យបាននូវអភិបាលកិច្ចល្អ។ ឯកសារនេះមានសារៈសំខាន់សម្រាប់គាំទ្រដល់ការអនុវត្ត សេចក្តីប្តេជ្ញាចិត្ត ដែលបានធ្វើឡើងនៅក្នុងកម្មវិធីនយោបាយ។

***នៅក្នុងកម្មវិធីនយោបាយនេះ ខុមហ្វ្រែល បានសង្កេតឃើញថា រហូតដល់ចុងឆ្នាំ២០០៥ មានតែសូចនាករដែលបានសន្យាប្រមាណតែ៥%ប៉ុណ្ណោះ ត្រូវបានបំពេញយ៉ាងពេញលេញ ចំណែក៨០%ទៀត ត្រូវបានបំពេញបានដោយផ្នែក និង១៥% ដែលនៅសល់ មិនទាន់ត្រូវបានបំពេញនៅឡើយ។***

ការរកឃើញជាទូទៅ មានរៀបរាប់ដូចខាងក្រោមនេះ :

- *ទៅលើទិដ្ឋភាពនយោបាយ យោងតាមអ្នកសង្កេតការណ៍ឯករាជ្យ និងអ្នកជំនាញការភាគច្រើនឱ្យដឹងថា រាជ-រដ្ឋាភិបាល__មានភាពធ្លាក់ចុះខ្សោយ__ ជាពិសេសដោយសារតែការរំលោភលើវិស័យសិទ្ធិមនុស្ស និងសេរីភាពបញ្ចេញមតិ។ លើសពីនេះទៀត ច្រើនជាង ៨០% នៃការសន្យាពាក់ព័ន្ធនឹងការបង្កើត ការធ្វើវិសោធនកម្ម និងការអនុម័តច្បាប់សំខាន់ៗ មិនទាន់ត្រូវបានបំពេញ ម្យ៉ាងទៀត ស្ថាប័នជាតិសំខាន់ៗមិនទាន់ត្រូវបានបង្កើត*

*ដូចដែលបានសន្យា និងមានតែការអនុវត្តន៍ដោយផ្នែកទៅលើចំណុចសំខាន់ផ្សេងទៀតដូចជា នៅក្នុងវិស័យកំណែទម្រង់វិស័យផ្សេងៗ។ (សូមមើលបន្ថែមចំណុចទី I ស្តីពីវិស័យនយោបាយនៅទំព័រទី៦)*

- *សម្រាប់ផ្នែកសេដ្ឋកិច្ច អ្នកសេដ្ឋកិច្ចវិទូភាគច្រើនវាយតម្លៃថា ការអនុវត្តការងាររបស់រាជរដ្ឋាភិបាល **<u>មានលក្ខណៈល្អ</u>** ព្រោះតែកំណើនសេដ្ឋកិច្ចមានអាត្រាខ្ពស់ទៅដល់គោលដៅនៃការសន្យា។ ទោះយ៉ាងណាក៏ដោយការបែងចែកកំណើននេះមិនមានភាពស្មើគ្នា ហើយមានបន្តកើតឡើងនូវការចែកដាច់ពីគ្នាកម្រិតខ្ពស់រវាងតំបន់ទីក្រុង និងជនបទ និងមានតម្រូវការ ជាបន្តឱ្យធ្វើការយកចិត្តទុកដាក់លើហេដ្ឋារចនាសម្ព័ន្ធ និងពហុវប្បកម្ម។ (សូមមើលបន្ថែមចំនុចទី II ស្តីពីវិស័យសេដ្ឋកិច្ចនៅទំព័រទី១០)*
- *ចំពោះវិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងវប្បធម៌វិញ ការអនុវត្តការងាររបស់រាជរដ្ឋាភិបាល**<u>មានលក្ខណៈជាមធ្យម</u>** ដោយមានសកម្មភាពជាច្រើនត្រូវបានធ្វើឡើង ដោយសារតែមានការគាំទ្រពីម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិ។ មានតម្រូវការជាបន្តទៀតនៅក្នុងវិស័យអប់រំ ការថែទាំសុខមាលភាព និងសិទ្ធិសម្រាប់កម្មករស្ត្រី និងកុមារ។ (សូមមើលបន្ថែមចំនុចទី III ស្តីពីវិស័យសង្គមកិច្ចនៅទំព័រទី១៣)*

***យ៉ាងហោចណាស់ មានការសន្យាពីដំបូងឡើយចំនួនប្រាំ ក្នុងចំណោមការសន្យាចំនួនប្រាំមួយចំណុច ដែលត្រូវសម្រេចឱ្យបានមុនដំណាច់ឆ្នាំ២០០៥*** ដោយរាជរដ្ឋាភិបាល ប៉ុន្តែរហូតមកទល់នឹងពេលនេះ ចំណុចទាំងនោះមិនទាន់ត្រូវបានអនុវត្តនៅឡើយ។ មានតែ១ចំណុចតែប៉ុណ្ណោះ ដែលត្រូវសម្រេចបានយ៉ាងពេញលេញនោះគឺ ការអនុម័តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សារាជសម្បត្តិ។ ***វិស័យសំខាន់ៗ ដែលមិនទាន់ត្រូវបានអនុម័តរួមមានដូចជា: ការអនុម័តច្បាប់ស្តីពីបាតុកម្ម និងកូដកម្ម ការអនុម័តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ជាមួយនឹងការបង្កើតស្ថាប័នអព្យាក្រឹត្យ និងឯករាជ្យមួយដើម្បីប្រឆាំងអំពើពុករលួយ និងការជ្រើសរើសមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ។***

ទាំងរាជរដ្ឋាភិបាល ទាំងរដ្ឋសភា បានធ្វើការប្រឹងប្រែងគួរឱ្យកោតសរសើរ ក្នុងការអនុម័តវិសោធនកម្មច្បាប់ ច្បាប់ថ្មី សន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង និងពិធីសារ ចំនួន៥២អត្ថបទ។ ទោះយ៉ាងណា ***ច្បាប់សំខាន់ៗសម្រាប់ជំរុញការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងសម្រាប់គាំទ្រដល់ការអភិវឌ្ឍប្រជាធិបតេយ្យ និងស្ថាប័នដែលរួមទាំងតួនាទីរបស់មតិជំទាស់ មិនទាន់ត្រូវបានអនុម័តនៅឡើយ។*** ទាំងនេះ គឺជាការសន្យាច្បាស់លាស់នៅក្នុងកម្មវិធីនយោបាយដែលរួមមាន : ***លក្ខន្តិកៈចៅក្រម ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសារការីសាធារណៈ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអាជ្ញាសាលា ច្បាប់ស្តីពីសមាជជាតិ និងការធ្វើវិសោធនកម្មលើច្បាប់ស្តីពីគណបក្សនយោបាយ។***

ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានធ្វើឡើង ប៉ុន្តែ ***ស្ថាប័នជាតិសំខាន់ដែលមានកំណត់នៅក្នុងកម្មវិធីនយោបាយមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ*** ដូចជា ***គណៈកម្មាធិការជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្រសួងអន្តោប្រវេសន៍*** និង***តុលាការឯកទេសមួយចំនួន*** ដូចជា***តុលាការការងារ តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការរដ្ឋបាល***។ រាជរដ្ឋាភិបាល និងរដ្ឋសភា ពិតជាបានបង្កើត***ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុក កិច្ចការព្រំដែន*** នៅក្នុងរយៈពេលមួយដ៏ខ្លីប៉ុន្តែបន្ទាប់មកក្រុមប្រឹក្សានេះត្រូវបានរំលាយទៅវិញ។ រាជរដ្ឋាភិបាលបានធ្វើការសិក្សា ហើយទំនងជាធ្វើការសម្រេចចិត្តថា មិនបង្កើតក្រសួងអន្តោប្រវេសន៍ទេ។

***រាជរដ្ឋាភិបាល បំពេញបានពេញលេញចំពោះការតម្លើងប្រាក់បៀវត្សរ៍ប្រមាណពី ១០% ទៅ ១៥% ក្នុងមួយឆ្នាំ ឱ្យដល់មន្ត្រីរាជការ*** ប៉ុន្តែកំណើននេះបានចូលរួមតែមួយផ្នែក សម្រាប់ទប់ទល់នឹងការកើនឡើងថ្លៃចំណាយលើជីវភាពប្រចាំថ្ងៃ ដោយសារតែមានការកើនឡើងយ៉ាងខ្លាំងនូវតម្លៃផលិតផល ដែលធ្វើឱ្យសេវាកម្មសាធារណៈនៅតែមិនទាន់មានប្រសិទ្ធភាព។ មានការកើនឡើងការិយាធិបតេយ្យ ដោយសារតែកិច្ចព្រមព្រៀងរាជរដ្ឋាភិបាលចម្រុះរវាងគណបក្សនយោបាយ ដែលបង្កើនចំនួនសមាជិករដ្ឋាភិបាលនៅក្នុងអាណត្តិទី ៣ រហូតដល់ចំនួន ១៧១ នាក់ ពោលគឺលើសចំនួន ៨០នាក់ ដែលជិតស្មើនឹង២ដងច្រើនជាងសមាជិកនៅអាណត្តិទី ២។ លើសពីនេះទៀត នីតិវិធីនីតិកម្មសម្របសម្រួល នៃយន្តការច្រកចេញចូលតែមួយ ត្រូវបានអនុវត្តបានដោយផ្នែកតែប៉ុណ្ណោះ។

ដូចគ្នានេះដែរ ការសន្យាធ្វើឱ្យប្រជាពលរដ្ឋកាន់តែទទួលបានសេវាកម្មសាធារណៈនៅតាមមូលដ្ឋាន តាមរយៈការិយាល័យថ្មី *"ច្រកចូលតែមួយ"* នោះ ត្រូវបានបំពេញនៅកម្រិតខ្សត់ខ្សោយមួយ ដោយមានតែការិយាល័យពីរត្រូវបានធ្វើការសាកល្បងនៅក្នុងប្រទេស រហូតមកទល់នឹងពេលនេះ ។

***រាជរដ្ឋាភិបាលបានបំពេញគោលដៅរបស់ខ្លួននូវកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ជាង៧% ហើយរាជរដ្ឋាភិបាលបានរៀបចំកម្មវិធីកំណែទម្រង់នៃការគ្រប់គ្រងហិរញ្ញវត្ថុតាមការសន្យា និងបានបង្កើនថវិកាជាតិឆ្នាំ២០០៥ រហូតដល់៥% និងថវិកាជាតិឆ្នាំ២០០៦ រហូតដល់២០%*** ។ ទោះយ៉ាងណាក៏ដោយ ***មិនមានប្រសិទ្ធភាព*** នៅក្នុងការអនុវត្ត និងការធានា ***ការបែងចែកផលប្រយោជន៍នៃកំណើនសេដ្ឋកិច្ចចំពោះវិស័យច្រើនទៀត*** ដូចជា ការងារអប់រំ សុខាភិបាល និងសង្គមកិច្ច ដែលត្រូវបានកំណត់ថា ជាវិស័យសំខាន់សម្រាប់ចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ។

មានការលើកឡើងថា រហូតមកដល់ពេលនេះ កង្វះជោគជ័យក្នុងការធានាឱ្យបានការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ចឱ្យកាន់តែមានភាពយុត្តិធម៌ គឺជាឧបសគ្គចម្បងចំពោះរាជរដ្ឋាភិបាល ដើម្បីសម្រេចឱ្យបានការសន្យានៅក្នុង កម្មវិធីនយោបាយ ពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច ។ ជាឧទាហរណ៍ ***រាជរដ្ឋាភិបាល មិនទាន់សម្រេចបាននៅឡើយនូវការធានាកម្រិតអប្បបរមានៃការអប់រំជាមូលដ្ឋានរយៈពេល៩ឆ្នាំសម្រាប់កុមារគ្រប់រូប ក៏ដូចជាការថែទាំសុខភាពដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព និងការរក្សាស្ថេរភាពថ្លៃនៃទំនិញជាមូលដ្ឋានដែលចាំបាច់សំរាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋទូទៅ ដូចជា ប្រេងឥន្ធនៈ និងស្បៀងអាហារសំខាន់ៗជាដើម ។***

***មានសេចក្តីស្នើច្បាប់ចំនួនពីរ ដែលស្ថិតនៅក្នុងការរង់ចាំ*** ហើយប្រសិនបើត្រូវបានអនុម័ត នោះអាចលើកស្ទួយដល់ការវិនិយោគបន្ថែមទៀតជាមួយនឹងផលប្រយោជន៍ស្មើភាពមួយឱ្យដល់ប្រជាជន និងជាតិ ។ ច្បាប់ទាំងនេះរួមមាន ***ច្បាប់ស្តីពីការគ្រប់គ្រងប្រតិបត្តិការកាស៊ីណូ និងល្បែងស៊ីសង*** ដែលអាចបង្កើតបាននូវការងារ និងប្រាក់ចំណូលចាំបាច់បានច្រើន ព្រមទាំង ***ច្បាប់ស្តីពីការគ្រប់គ្រងតំបន់ឧស្សាហកម្ម*** ដែលគួរតែជំរុញឱ្យមានសកម្មភាពពាណិជ្ជកម្ម និងសហគ្រាសថ្មីៗ ប៉ុន្តែក្នុងករណីមិនមានបទបញ្ញត្តិសមស្របទេ នោះអាចនឹងនាំឱ្យផលប្រយោជន៍ទាំងនោះហូរចេញទៅក្រៅប្រទេស ។

បញ្ហាដីធ្លីនៅតែមានភាពចម្រូងចម្រាស់ រាជរដ្ឋាភិបាលបានសម្រេចការងារបានមួយចំនួន ប៉ុន្តែមិនបានទាំងស្រុងនូវ ***ការពិនិត្យមើលឡើងវិញនូវដីទំនេររបស់រដ្ឋ ឬដីរដ្ឋដែលឯកជនកាន់កាប់ ការចេញប័ណ្ណសំគាល់កម្មសិទ្ធិដីធ្លី ជាពិសេសឱ្យដល់ជនក្រីក្រ និងជនងាយរងគ្រោះ ។ រាជរដ្ឋាភិបាល មិនទាន់បានធ្វើសកម្មភាពក្នុងការបែងចែកដីធ្លីក្នុងក្របខណ្ឌនៃសម្បទានដីសង្គមកិច្ចនៅឡើយ ។*** យោងតាមអង្គការសិទ្ធិមនុស្ស និងអង្គការផ្នែកច្បាប់ឱ្យដឹងថា នៅតែបន្តមានការចាប់យក និងការទន្ទ្រានយកដីរបស់រដ្ឋ ដែលមិនប្រើប្រាស់ដោយអ្នកមានលុយ និងអំណាច ។

ទោះបីជាការឃ្លាំមើលសភា បង្ហាញថា ***ចំនួនទស្សនកិច្ចរបស់សមាជិករដ្ឋសភាទៅកាន់មណ្ឌលរៀងៗខ្លួន*** និងការសម្តែងមតិ និងសកម្មភាពរបស់ពួកគេនៅក្នុងរដ្ឋសភា ***មានការកើនឡើងពីមួយខែ ទៅមួយខែក៏ដោយ ក៏ប្រសិទ្ធភាព នៃការអនុវត្តន៍សិទ្ធិ និងអំណាចរបស់ពួកគេជាសមាជិកសភានៅតែមានកំរិត*** ។ បញ្ហានេះកើតមានជាពិសេសចំពោះ ***អំណាចត្រួតពិនិត្យ និងតុល្យភាព*** របស់អង្គនីតិបញ្ញត្តិទៅលើសកម្មភាពរបស់អង្គនីតិប្រតិបត្តិពោលគឺរាជរដ្ឋាភិបាល ។ ការសង្កេតបង្ហាញថា ***សមាជិករាជរដ្ឋាភិបាលមិនចូលរួមឱ្យបានទៀងទាត់ មិនឆ្លើយសំណួរ ឬមិនចូលរួមពិភាក្សា វែកញែកដេញដោលដោយសកម្មនៅក្នុងរដ្ឋសភាឡើយ ។*** មានតែរដ្ឋមន្ត្រីនៃក្រសួងពីរប៉ុណ្ណោះដែលបានឆ្លើយតបជាវិជ្ជមានចំពោះការអញ្ជើញយ៉ាងហោចចំនួន ១០ របស់សមាជិករដ្ឋសភា ។

ខាងក្រោមនេះជារបាយការណ៍សង្ខេបតាមវិស័យនិមួយៗ :

## I- វិស័យនយោបាយ

សំរាប់**វិស័យនយោបាយ** យោងទៅតាមអ្នកសង្កេតការណ៍ និងអ្នកជំនាញការឯករាជនានា ការបំពេញការងាររបស់រាជរដ្ឋាភិបាល ***មានលក្ខណៈខ្សោយ*** ។ លទ្ធផល (មានសូចនាករច្បាស់លាស់ និងជាគោលបំណង) បង្ហាញថា សូចនាករដែលបានសន្យាប្រមាណ២៨% មិនទាន់បានបំពេញ និង៧២% ទៀតត្រូវបានបំពេញដោយផ្នែកខ្លះប៉ុណ្ណោះ ។ ជាពិសេសនៅ

មានការរំលោភសិទ្ធិពលរដ្ឋ និងគោលការណ៍នៃប្រជាធិបតេយ្យ សេរីពហុបក្ស ដែលធ្វើឱ្យប៉ះពាល់ដល់សាមគ្គីភាពជាតិ ។ ពុំទាន់ប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្ត ក្នុងការធានានូវ សេរីភាពបញ្ចេញមតិជាសាធារណៈ និងសេរីភាពសារព័ត៌ឡើយ ព្រមទាំងមានការលើកទឹកចិត្តដ៏តិចតួចចំពោះការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាមួយរាជរដ្ឋាភិបាល ។



ឯ.ឧ សម រង្ស៊ី

របាយការណ៍ស្ថានភាពសិទ្ធិមនុស្សរបស់អង្គការអាដហុកឆ្នាំ២០០៥ ឱ្យដឹងថា ស្ថានភាពកាន់តែអាក្រក់ ពេញមួយឆ្នាំកន្លងមកនេះ: ***"ក្នុងឆ្នាំ២០០៥ មាន ការចាប់ខ្លួនជាច្រើន និងការដាក់ទណ្ឌកម្មដោយតុលាការប្រឆាំងមនុស្សក្នុងគណបក្សជំទាស់"*** ។

លោក **ភីថឺរ លយ៍ប្រែកតឺ** តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានមានប្រសាសន៍ថា: *"មានការចាត់វិធានការផ្សេងៗទៅលើគណបក្ស ជំទាស់ដោយ* ***រំលោភទៅលើគោលការណ៍ជាមូលដ្ឋានស្តីពីសិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស*** *។ អ្វីដែលយើងឃើញក្នុងពេលបច្ចុប្បន្ននេះ គឺជាការគួរឱ្យសោកស្តាយ ដែលវាមិនបានបង្ហាញឱ្យឃើញថា មានការរីកចំរើននៅលើផ្លូវមួយឆ្ពោះទៅកាន់សិទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ផ្ទុយទៅវិញ គេសង្កេតឃើញមានការកើនឡើងនៃទម្រង់រដ្ឋាភិបាលអត្តាធិបតេយ្យ និងការប្រមូលផ្តុំអំណាចនៅក្នុងដៃរបស់នាយករដ្ឋមន្ត្រីដែលស្ថិតនៅពីក្រោយមុខមាត់លិទ្ធិប្រជា-ធិបតេយ្យមិនរឹងមាំ"* ចំណែកឯកអគ្គរដ្ឋទូត សហរដ្ឋអាមេរិកលោក **ឆាល រេ** បានវាយតម្លៃថា: ***"ដំណើរការអនុវត្តលទ្ធិប្រជា-ធិបតេយ្យនៅក្នុងប្រទេសកម្ពុជា គឺយឺត"*** ។

របាយការណ៍ស្ថានភាពសិទ្ធិមនុស្សរបស់អង្គការអាដហុកឆ្នាំ ២០០៤ និងឆ្នាំ ២០០៥ បានគូសបញ្ជាក់អំពីបញ្ហាសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនានាដូចជា *"ការព្រួយបារម្ភស្តីពីការបន្ថយសេរីភាពក្នុងការជួបប្រជុំ ការកើនឡើងដ៏គួរឱ្យកត់សំគាល់នូវទំនាស់ដីធ្លីដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅលើសិទ្ធិក្នុងការមានកម្មសិទ្ធិរបស់ជនក្រីក្រ និងអ្នកគ្មានអំណាច* ។ ការិយាល័យសហរដ្ឋអាមេរិកសំរាប់កិច្ចការលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ និងសមាគមអាដហុក បានរកឃើញថា សិទ្ធិនយោបាយ សេរីភាពអង្គការសមាគម សេរីភាពសារព័ត៌មាន និងសេរីភាពទទួលព័ត៌មាន កាន់តែអាក្រក់ជាមួយនឹងការត្រួតពិនិត្យ ឬឥទ្ធិពលពីរដ្ឋាភិបាល ទៅលើខ្លឹមសារនៃការផ្សព្វផ្សាយ តាមរយៈវិទ្យុ និងទូរទស្សន៍ ។ របាយការណ៍សេរីភាពសារព័ត៌មានឆ្នាំ២០០៥ ដោយ Freedom House បានបញ្ជាក់ថា *"មិនមានភាពសេរីសំរាប់សារព័ត៌មាន..មានសមាជិកសារព័ត៌មានមួយចំនួនត្រូវបានប្តឹងពីបទបរិហារកេរ្តិ៍ក្នុងកំឡុងឆ្នាំ២០០៤ ហើយមានអ្នកសារ-ព័ត៌មាន ២នាក់ត្រូវបានកាត់សេចក្តីឱ្យបង់ប្រាក់ពិន័យដល់ដើមបណ្តឹង"* ។ ក្នុងឆ្នាំ២០០៥ នៅថ្ងៃទី ១១ ខែតុលា លោក **ម៉ម សូណង់ដូ** នាយកវិទ្យុសំបុកឃ្មុំត្រូវបានចាប់ខ្លួនឃុំនៅពន្ធនាគារពីបទបរិហារកេរ្តិ៍ ។



លោក ម៉ម សូណង់ដូ

យោងតាមរបាយការណ៍អាដហុកពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០០៥ យ៉ាងហោចណាស់មានការបង្ក្រាបទៅលើបាតុកម្ម និងកូដកម្មដោយសន្តិវិធី ចំនួន៤០ករណី (ក្នុងចំណោម ៣៤១ ករណីដែលបានរាយការណ៍ដោយក្រសួងមហាផ្ទៃនៅក្នុងរបាយ-ការណ៍ឆ្នាំ២០០៤ និង២០០៥ របស់ខ្លួន) ។ ការបង្ក្រាបរួមមានការប្រើដំបងឆក់ និងការបាញ់ឡើងទៅលើ និងការបាញ់ឧស្ម័ន បង្ហូរទឹកភ្នែក ដែលបានបង្ករបួសស្នាម ព្រមទាំងរហូតដល់មានការបាត់បង់ជីវិតអ្នកភូមិ ៥នាក់នៅក្នុង ខេត្តបន្ទាយមានជ័យ ។ នៅខែមិថុនា ឆ្នាំ២០០៥ ការរៀបចំវេទិកាសាធារណៈ របស់អង្គការមិនមែនរដ្ឋាភិបាល នៅតាមទីវត្តអារាមត្រូវបានហាមប្រាម ។



ការបង្ក្រាបបាតុករនៅខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាលបានបំពេញទាំងស្រុងនូវការសន្យាក្នុងការតម្លើងប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិលពី ១០% ទៅ ១៥% ក្នុងមួយឆ្នាំ ។ ប៉ុន្តែការកើនឡើងនេះ មិនបានចូលរួមដល់ការកើនឡើងនូវការចំណាយ និងជីវភាពរស់នៅគ្រប់គ្រាន់ឡើយ ព្រោះថា ថ្លៃទំនិញកើនឡើងយ៉ាងខ្លាំង ។ ហើយជាលទ្ធផលសេវាកម្មសាធារណៈ នៅតែមិនមានប្រសិទ្ធភាព ។ *"ទាំងអស់គ្នាទទួលស្គាល់ថា ប្រាក់បៀវត្សរ៍បច្ចុប្បន្នមានកម្រិតទាបខ្លាំងណាស់"* ។

មានច្បាប់មួយចំនួន ត្រូវបានធ្វើវិសោធនកម្ម និងអនុម័ត ។



សមាជិកសភាលើកដៃអនុម័តច្បាប់

ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់សំខាន់ដ៏ទៃទៀតមិនត្រូវបានអនុម័តនៅឡើយទេ ដែលរួមមាន ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិ ច្បាប់ស្តីពីបាតុកម្ម និងកូដកម្ម ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ច្បាប់គ្រប់គ្រងកាស៊ីណូ ច្បាប់ស្តីពីតំបន់ឧស្សាហកម្ម ក្នុងចំណោមច្បាប់ដ៏ទៃផ្សេងទៀត។ ជាង ៨០% នៃការសន្យាក្នុងការបង្កើត ការធ្វើវិសោធនកម្ម និងការអនុម័តច្បាប់សំខាន់ៗ មិនត្រូវបានបំពេញទេ។ នីតិរដ្ឋពុំត្រូវបានពង្រឹង។

ការបង្កើតស្ថាប័នជាតិសំខាន់ៗ មិនបានបំពេញតាមការសន្យា ដែលរួមមានដូចជា គណៈកម្មាធិការជាតិសិទ្ធិមនុស្ស ក្រសួងអន្តោប្រវេសន៍ ការរៀបចំប្រធាន អនុប្រធាន និងសមាជិកភូមិ ការរៀបចំឱ្យមាននូវតុលាការឯកទេសមួយចំនួនតាមតម្រូវការចាំបាច់ (ជាអាទិ៍តុលាការពាណិជ្ជកម្ម តុលាការអនីតិជន តុលាការការងារ និងតុលាការរដ្ឋបាល) និងស្ថាប័ននានា សំរាប់បណ្តុះបណ្តាលមន្ត្រីដែលមានសាវតាផ្សេងៗគ្នា។ ទោះបីជាក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ត្រូវបានបង្កើតឡើងក្នុងរយៈពេលយ៉ាងខ្លី តាមរយៈការប្រទានព្រះរាជក្រឹត្យ ប៉ុន្តែក្រោយមកក្រុមប្រឹក្សានេះត្រូវបានរំលាយចោលទៅវិញ។



ឯ.ឧ សុខ អាន

ចំពោះ**កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ** ឯ.ឧ.**សុខ អាន** បានទទួលស្គាល់ថា *"ការរីកចម្រើនមានល្បឿនយឺតពេក"*។ ការសង្កេតមើលឃើញថា ច្បាប់សំខាន់ៗសម្រាប់គាំទ្រការកែទម្រង់ប្រព័ន្ធយុត្តិធម៌មិនទាន់បានអនុវត្ត ។ ព្រះរាជក្រិត្យស្តីពីការចូលនិវត្តន៍ របស់ចៅក្រមដែលមានអាយុចាប់ពី ៦០ ឆ្នាំឡើង ត្រូវបានឡាយព្រះហស្ថលេខា នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០០៥ ក៏ដោយ ក៏រហូតមកដល់ពេលនេះមិនមានចៅក្រមណាម្នាក់ ត្រូវបានតម្រូវឱ្យចូលនិវត្តន៍នៅឡើយទេ។



សុខ សំអឿន និងប៊ិន សំណាង

ករណីចោទប្រកាន់ **ប៊ិន សំណាង** និង **សុខ សំអឿន** អំពីបទមនុស្សឃាតប្រព្រឹត្តិលើមេដឹកនាំសហជីព លោក **ជា វិជ្ជា** លោក **ភីថឺរ លយ** ប្រែកតឺ បានពោលថា *"ការកាត់សេចក្តីខុកខានមិនបានបង្ហាញភស្តុតាងណាមួយ ដែលភ្ជាប់ការពាក់ព័ន្ធរវាងជនជាប់ចោទទៅនឹងបទឧក្រិដ្ឋ ហើយមិនបានយកចិត្តទុកដាក់ដល់គោលការណ៍ជាមូលដ្ឋាននៃការកាត់សេចក្តីដោយយុត្តិធម៌ ដូចជាការសន្មត់ទុកជាមុនថា គ្មានទោស និងភាពមិនលម្អៀងរបស់តុលាការ។...សាលក្រមទាំងនោះ ក៏បាននាំមកនូវកង្វល់ជាថ្មីម្តងទៀតអំពីឯករាជ្យភាពរបស់តុលាការកម្ពុជា ខណៈពេលដែលលោកនាយករដ្ឋមន្ត្រី* ***ហ៊ុន សែន*** *បានប្រកាសពីគោលនយោបាយកណ្តាប់ដៃដែក ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងស្ថាប័នតុលាការ។ គោលនយោបាយនេះបានដាក់ទណ្ឌកម្មដល់មន្ត្រីតុលាការជាច្រើននាក់ ដោយគ្មាននីតិវិធីដាក់វិន័យត្រឹមត្រូវ ហើយបានធ្វើឱ្យខូចខាតថែមទៀតដល់ឯករាជ្យភាពរបស់តុលាការ"*។ ហេតុផលនេះហើយ ដែលបណ្តាលឱ្យនៅតែមានការព្រួយបារម្ភចំពោះការតែងតាំងចៅក្រមសម្រាប់តុលាការខ្មែរក្រហម (គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ឆ្នាំ ២០០៥)។

នៅក្នុងផ្នែកផ្សេងទៀត មានតែការសន្យាមួយចំនួនប៉ុណ្ណោះត្រូវបានអនុវត្ត ក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការរំសាយកងទ័ព ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណែទម្រង់ការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ។ រាជរដ្ឋាភិបាលក៏មិនបានបំពេញឱ្យបានពេញលេញផងដែរ នូវការសន្យារបស់ខ្លួនចំពោះគោលនយោបាយសន្តិសុខជាតិ និងគោលនយោបាយក្រៅប្រទេស។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មិនទាន់ត្រូវបានយល់នៅក្នុងចំណោមក្រសួងនានានៅឡើយ ដែលបណ្តាលឱ្យមានការដណ្តើមសមត្ថកិច្ចរវាងក្រសួងពាក់ព័ន្ធ។ បញ្ហានេះបានធ្វើឱ្យស្មុគស្មាញ ដោយសារទម្លាប់ និងចរិតដែលមានស្រាប់របស់រដ្ឋបាលកណ្តាល ហើយនិងមូលហេតុដែលថា ដំណើរការនេះបានត្រូវការរយៈពេលយូរ (ក្រសួងមហាផ្ទៃឆ្នាំ ២០០៦)។ របាយការណ៍ជាច្រើនពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល ដែលខិតខំបង្កើតដៃគូជាវិជ្ជមានជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់បានបង្ហាញថា សេចក្តីណែនាំស្តីពីការគាំទ្រក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលចេញនៅខែមិថុនា ឆ្នាំ២០០៥ ដោយក្រសួងមហាផ្ទៃបាន

បង្កើតឧបសគ្គ និង**អប្រសិទ្ធភាពមិនចាំបាច់** ដល់ការគាំទ្ររបស់ខ្លួនចំពោះក្របខណ្ឌយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រផ្សេងទៀតរបស់រាជរដ្ឋាភិបាល ។ ការធ្វើវិមជ្ឈការហិរញ្ញវត្ថុឃុំ-សង្កាត់ មិនទាន់ត្រូវបានអនុវត្តនៅឡើយ ។

នៅឆ្នាំ ២០០៥ *"ប្រទេសកម្ពុជាបានលេចចេញជាលើកទីមួយនៅក្នុងប្រព័ន្ធចំណាត់ថ្នាក់អន្តរជាតិមួយចំនួន ដូចជា សន្ទស្សន៍ការយល់ដឹងអំពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ និងសន្ទស្សន៍នៃភាពប្រកួតប្រជែងកើនឡើងរបស់វេទិកាសេដ្ឋកិច្ចពិភពលោក... ។ កម្ពុជាជាប់ចំណាត់ថ្នាក់ស្ទើរតែនៅបាតគេចំពោះចំណាត់ថ្នាក់ទាំងពីរនេះ"* ។ ទោះបីជាមានការផ្តល់យោបល់ និងការពិនិត្យសើរើជាបឋមមួយចំនួន *"វាជាការរំដើបរំជួលមួយដែលថា សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយនៅបច្ចុប្បន្ននេះខកខានមិនបំពេញបានតាមបទដ្ឋានអន្តរជាតិឡើយ...មានករណីអំពើពុករលួយតិចតួច ដែលបញ្ជូនទៅដល់តុលាការ"* (មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ២០០៦ : ២២) ។

ចំពោះបញ្ហានៃការផ្តល់កម្មសិទ្ធិដីធ្លីវិញ សម្តេច **ហ៊ុន សែន** បានទទួលស្គាល់ថា ***ដំណើរការផ្តល់កម្មសិទ្ធិដីមានភាពយឺតយ៉ាវ ។*** មានការកើនឡើងនូវការិយាធិបតេយ្យ ដោយសារតែកិច្ចព្រមព្រៀងសម្ព័ន្ធភាពរវាងគណបក្សនយោបាយ ដែលបានបង្កើនចំនួនសមាជិករាជរដ្ឋាភិបាល នៅអាណត្តិទីបីនេះរហូតដល់១៧១នាក់ ពោលគឺកើនលើស៨០នាក់ ជិតស្មើនឹងពីរដងនៃចំនួនសមាជិករាជរដ្ឋាភិបាលអាណត្តិទីពីរ ។ *"បញ្ហាប្រឈមធ្ងន់ធ្ងរនៅតែមានទៅលើបញ្ហាការងារធ្វើ [នៅក្នុងសេវាសាធារណៈ]"* (អៀនផតធ័រ ២០០៦) ។

*រាជរដ្ឋាភិបាល* ***មិនទាន់បានបំពេញការចុះបញ្ជី និងបែងចែកដីធ្លី ហើយនិងការជំរុញឱ្យមានសុវត្ថិភាពកាន់កាប់ដីធ្លី*** នៅឡើយ នៅក្នុងក្របខណ្ឌនៃសម្បទានដីសង្គមកិច្ច ។ មានត្រឹមតែ ២០% ប៉ុណ្ណោះ នៃអ្នកកាន់កាប់ដីនៅកម្ពុជា មានប័ណ្ណកម្មសិទ្ធិដីរបស់ខ្លួន (កម្មវិធីដីធ្លីនិងជីវិត២០០៦) ។នៅឆ្នាំ២០០៥ *"អង្គការមិនមែនរដ្ឋាភិបាលមួយបានរាយការណ៍អំពីការទទួលពាក្យបណ្តឹងក្នុងរយៈពេល១ឆ្នាំចំនួន១៣០ករណីស្តីពីទំនាស់ដីធ្លី ដែលបានប៉ះពាល់ដល់ប្រជាជនចំនួន ៧.៨៨៥ គ្រួសារ"* ។ មានករណីមួយដែលរាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានដល់ក្រុមហ៊ុនភាពីម៉ិចនូវដីទំហំ ៣១៥.០២៨ ហិកតា នៅខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់ ដែលជាការរំលោភលើច្បាប់ភូមិបាល ដោយទំហំដីសម្បទាននោះមានទំហំ ៣០ ដង ច្រើនជាងច្បាប់កំណត់ ។ យោងតាមធនាគារពិភពលោក (នៅឆ្នាំ២០០៦) ភាពគ្មានដីធ្លីកំពុងកើនឡើង : *"សមាមាត្រនៃគ្រួសារនៅជនបទដែលខ្វះដីសម្រាប់ការដាំដុះបានកើនឡើងពី១៣% ក្នុងឆ្នាំ១៩៩៧ ទៅដល់១៦% ក្នុងឆ្នាំ១៩៩៩ និង ២០% នៅឆ្នាំ២០០៤..."* ។



សមត្ថកិច្ច បង្ក្រាបការតវ៉ារបស់ប្រជាពលរដ្ឋ

ទោះបីជាមានការចងក្រងឯកសារស្តីពីទីតាំងព្រៃឈើសហគមន៍ច្រើនជាង ២០០ ដោយរដ្ឋបាលព្រៃឈើក៏ដោយ ក៏ *"មិនមានព្រៃឈើសហគមន៍ត្រូវបានទទួលស្គាល់ដោយរដ្ឋបាលព្រៃឈើឡើយ ហើយប្រកាសដែលផ្តល់សេចក្តីណែនាំសម្រាប់ព្រៃឈើសហគមន៍ មិនទាន់ត្រូវបានអនុម័តនៅឡើយ"* (ដីធ្លី និងកម្មវិធីជីវិត ២០០៦) ។ *ឧបសគ្គចម្បងៗ...រួមមានដូចជា ការមិនធានាសិទ្ធិកម្មសិទ្ធិលើធនធានដែលនៅក្រោមការគ្រប់គ្រងរួម និងការបំផ្លាញមូលធនសង្គម មកពីលទ្ធផលនៃជម្លោះហិង្សារយៈពេល៣០ឆ្នាំ ។ ខណៈមានឱកាសក្នុងការផ្តល់ឱ្យប្រជាជនក្នុងស្រុកនូវការត្រួតពិនិត្យលើព្រៃឈើ មានតែតំបន់ដែលត្រូវបំផ្លាញដែលមានតម្លៃឈើទាបប៉ុណ្ណោះត្រូវបានបែងចែកជាព្រៃឈើសហគមន៍"* ការប្រើប្រាស់សម្បទានព្រៃឈើដោយខុសច្បាប់នៅតែត្រូវបានរាយការណ៍ជារឿយៗ ដោយបណ្តាញព័ត៌មាន និងអង្គការឃ្លាំមើលជាតិ និងអន្តរជាតិ ។ មានការកើនឡើងនូវអំពើហិង្សា និងការគំរាមកំហែងដល់ តួអង្គសង្គមស៊ីវិល និងមន្ត្រីនៅក្នុងវិស័យនេះ ដោយរុក្ខាររក្ស ២ នាក់ត្រូវបានសម្លាប់ នៅថ្ងៃទី ២៧ កញ្ញា ២០០៥ និងម្នាក់ទៀតនៅខែ សីហា ២០០៥ ហើយនិងមានការប៉ុនប៉ងបាញ់ ២ នាក់ ទៀត នៅខែកក្កដា ឆ្នាំ២០០៥ ។ ការរំលោភចាប់យកដីត្រូវបានចាត់ទុកថាជា *"បញ្ហាចម្បងមួយ"* (Thanakvaro ២០០៥) ។

ទោះជាយ៉ាងនេះ នៅក្នុងផែនការកាត់រំសាយទ័ព ដែលគាំទ្រដោយធនាគារពិភពលោក មានទាហានចំនួន៣០ ០០០នាក់ត្រូវកាត់រំសាយ ប៉ុន្តែមានតែចំនួន ១៦៥០០នាក់ប៉ុណ្ណោះត្រូវបានរំសាយមកទល់នឹងឆ្នាំ២០០៣ ។ លោក **ធន សារាយ** ប្រធានសមាគមអាដហុក បាននិយាយដោយយោងទៅដល់បញ្ហាសុវត្ថិភាព និងការកើតឡើងនូវបទល្មើសថា *"មូលហេតុចម្បងៗ ដែលនាំទៅដល់ការកើតឡើងនូវបទល្មើសនៅពាសពេញប្រទេសមានដូចជា ការអនុញ្ញាតឱ្យមានបនល្បែងស៊ីសង (កាស៊ីណូ) ភាព*

*គ្មានការងារធ្វើកើនឡើង ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការបាត់បង់ជំនឿទុកចិត្តលើប្រព័ន្ធតុលាការ និងការពង្រឹងសមត្ថភាពកងកម្លាំងមានសមត្ថកិច្ចមិនបានត្រឹមត្រូវ។ ហើយមូលហេតុទាំងអម្បាលម៉ាននេះ មិនត្រូវបានយកចិត្តទុកដាក់ទប់ស្កាត់ ឬបង្ក្រាបឱ្យមានប្រសិទ្ធភាពឡើយ។"* ប្រទេសកម្ពុជាពុំទាន់មានច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មនៅឡើយទេ។ ក្នុងឆ្នាំ ២004 លោក Graham Shaw មន្ត្រីកម្មវិធីនៃការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងបទឧក្រិដ្ឋ (UNODC) បាននិយាយថា *"ការជួញដូរគ្រឿងញៀននៅកម្ពុជាមិនអាចគ្រប់គ្រងបាន"*។

គណៈកម្មការសិទ្ធិមនុស្សអាស៊ី (ឆ្នាំ ២០០៦) ឱ្យដឹងថា *"កិត្យានុភាពរបស់កម្ពុជាលើឆាកអន្តរជាតិ... ត្រូវបានធ្វើឱ្យស្រអាប់យ៉ាងខ្លាំង ដោយព្រឹត្តិការណ៍កាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ នៅខណៈពេលដែលបទបរិហារកេរ្តិ៍ត្រូវបានប្រើប្រាស់ ដើម្បីបង្កការភ័យខ្លាចដល់អ្នកជំទាស់នឹងរដ្ឋាភិបាល ព្រមទាំងប្រជាជនជាទូទៅផងដែរ"*។ មានមន្ទិលសង្ស័យទៅលើរយៈកាលកំណត់ចំពោះនិន្នាការរបស់រាជរដ្ឋាភិបាល ក្នុងទំនាក់ទំនងដោយលម្អៀងជាមួយបណ្តាប្រទេសកាន់របបផ្តាច់ការ និងកុំម្មុយនីស្ត ដូចជាប្រទេសភូមា ចិន វៀតណាម និងឡាវ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអំពីជំហររបស់ខ្លួន ក្នុងការផ្តល់ការគាំទ្រដល់ ប្រទេសភូមានៅអាស៊ាន ហើយបានថ្លែងថា ការរំលោភសិទ្ធិមនុស្សនៅប្រទេសភូមា គឺជាបញ្ហាផ្ទៃក្នុងរបស់ប្រទេសនេះ: *"កម្ពុជានឹងមិនចូលរួមហើយថែមទាំងជំទាស់ចំពោះចលនានៃការទប់ស្កាត់សិទ្ធិរបស់ប្រទេសភូមាក្នុងកិច្ចការអាស៊ានទៀតផង*។

## II- វិស័យសេដ្ឋកិច្ច

ចំពោះ**វិស័យសេដ្ឋកិច្ច**វិញ សេដ្ឋវិទូជាច្រើនបានវាយតម្លៃថា ការបំពេញភារកិច្ចរបស់រាជរដ្ឋាភិបាលមានលក្ខណៈល្អប្រសើរ ដោយសារតែកំណើនសេដ្ឋកិច្ចមានកំរិតខ្ពស់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍ និងអ្នកជំនាញការឯករាជខ្លះបញ្ជាក់ថា ការបំពេញការងាររបស់រាជរដ្ឋាភិបាល ***មានលក្ខណៈមធ្យម*** ជាពិសេស កំណែទម្រង់ហិរញ្ញវត្ថុនៅមានការយឺតយ៉ាវ ហើយការបែងចែកកំណើននេះមិនមានសមភាព។ លទ្ធផលទាក់ទងទៅនឹងវិស័យសេដ្ឋកិច្ចនេះបង្ហាញថា មានសូចនាករប្រមាណតែ ១២% ត្រូវបានបំពេញទាំងស្រុង ក្នុងខណៈពេលដែលការសន្យាភាគច្រើនរហូតដល់ ៧៦% ត្រូវបានបំពេញតែផ្នែកខ្លះប៉ុណ្ណោះ និង ១២% ទៀតមិនត្រូវបានបំពេញទាំងស្រុង។

លោក Miloon Kothari អ្នករាយការណ៍ពិសេសស្តីពីការតាំងលំនៅដ្ឋានសមរម្យ របស់ឧត្តមស្នងការសម្រាប់ជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិ បានសម្តែងការព្រួយបារម្ភថា ការផ្ទេរទ្រព្យសម្បត្តិសាធារណៈនៅតែប្រព្រឹត្តទៅដោយគ្មានតម្លាភាព ឬការចូលរួមរបស់សាធារណជន។ មានការសង្កេតឃើញថា អំណាចនីតិបញ្ញត្តិមានភាពទន់ខ្សោយ ដែលមិនអាចធ្វើឱ្យយន្តការត្រួតពិនិត្យរាជរដ្ឋាភិបាលកម្ពុជា មានភាពប្រសើរឡើង ឬក៏ដើម្បីធានាតុល្យភាពរវាង អំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ។

វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ក៏បានធ្វើការកំណត់វិស័យមួយចំនួន ដែលរាជរដ្ឋាភិបាលកម្ពុជា អនុវត្តមិនបានល្អ ដូចជាការទាមទារឱ្យមានប្រាក់បម្រុងចំនួន ៨% មិនត្រូវបានកែតម្រូវ ប្រាក់កក់ធានាចំនួន ១០% មិនត្រូវលុបបំបាត់ រាជរដ្ឋាភិបាលកម្ពុជាមិនបានធានាឱ្យមានអនុម័តតារាងគណនីយកសម្រាប់ស្ថាប័នហិរញ្ញវត្ថុ និងធនាគារទាំងអស់ ច្បាប់ស្តីពីការលាងលុយនៅតែស្ថិតជាសេចក្តីព្រាង ការធ្វើឯកជនភាវូបនីយកម្មធនាគារពាណិជ្ជក្រៅប្រទេស ត្រូវបានពន្យារពេល ច្បាប់ស្តីពីឧបករណ៍ដែលអាចលក់បាន និងប្រតិបត្តិការបង់ប្រាក់នៅតែស្ថិតនៅរដ្ឋសភា កម្មវិធីបណ្តុះបណ្តាលជាថ្មី បែបទូលំទូលាយឱ្យដល់បុគ្គលិកធនាគារជាតិដែលមិនមានសញ្ញាប័ត្រមធ្យមសិក្សា មិនទាន់ត្រូវបានបង្កើតឡើង ហើយវិទ្យាស្ថានប្រកបដោយវិជ្ជាជីវៈសម្រាប់ធនាគារិកមិនត្រូវបានបង្កើត។

ការសង្កេតឃើញមានកំណើនខ្ពស់ និងស្ថេរភាពអតិផរណានៅក្នុងកំឡុងពេលអង្កេតនេះ ហើយរាជរដ្ឋាភិបាលបំពេញបានទាំងស្រុងនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្ម។ ការលើកទឹកចិត្ត ចំពោះសហគ្រាសធនតូច និងមធ្យមមានដំណើរការល្អខ្លះ។ រាជរដ្ឋាភិបាលបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងអាស៊ាន និងបានធ្វើឱ្យមានការវិវត្តន៍ខ្លះចំពោះពាណិជ្ជកម្មសេរី។ កំពង់ផែរត្រូវបានបង្កើតបន្ថែមថ្មីដូចបានសន្យា។ បើទោះបីជាយ៉ាង

ណាក៏ដោយ ការបំពេញការងារមិនសូវរឹងមាំនៅក្នុងផ្នែកផ្សេងៗទៀតរួមមាន អាត្រាប្តូរប្រាក់ កំណែទម្រង់ និងការប្រមូលពន្ធដា ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ប្រតិបត្តិការថវិកា និងការពង្រឹងប្រព័ន្ធធនាគារក្នុងស្រុក។ មិនមានការរៀបចំធ្វើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូនៅឡើយ។ មានបញ្ហាជាច្រើននៅក្នុងវិស័យកសិកម្ម ទាក់ទងនឹងការធ្វើពហុវប្បកម្ម និងការអភិវឌ្ឍទីផ្សារ ហើយហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធធារាសាស្ត្រនៅតែត្រូវការការអភិវឌ្ឍ។

យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទោះបីវិស័យកសិកម្មជាវិស័យចូលរួមដល់ ផលិតផលក្នុងស្រុកសរុប (ផសស) ជាមធ្យមខ្ពស់បំផុតក៏ដោយ ក៏វិស័យនេះបានធ្លាក់ចុះពី ៣៩,៤% មកនៅ ៣០,៩% ក្នុងរវាងពីឆ្នាំ១៩៩៩ មកដល់ឆ្នាំ២០០៤ (បណ្ឌិត **ហង់ ជួនណារ៉ុន** ២០០៦)។ ទន្ទឹមនឹងនេះ ធនាគារពិភពលោក (២០០៦ខ) ឱ្យដឹងថា *"ផលិតភាព និងភាពអាចចំណេញនៃវិស័យកសិកម្មទាប ភាពគ្មានដីធ្លីចេះតែកើនឡើង និងការទទួលបានជាមួយនឹងភាពមានស្រាប់នូវធនធានទ្រព្យសម្បត្តិរួម ដែលចេះតែធ្លាក់ចុះ បានកាន់តែបន្ថយថែមទៀតនូវឥទ្ធិពលកំណើនទៅលើភាពក្រីក្រនៅជនបទ"*។ ធនាគារពិភពលោកបន្តអះអាងថា កំណើនវិស័យកសិកម្មមានកម្រិតទាប (ជាមធ្យមមានចំនួន៣,២% ក្នុងមួយឆ្នាំធៀបនឹងទិសដៅរបស់ធនាគារដែលមានចំនួន៤,៥%)។

លោកបណ្ឌិត **យ៉ាង សាំងកុមារ** ប្រធានអង្គការសេដាក (មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា) បានឱ្យដឹងថា: *"ការអនុវត្តជាក់ស្តែងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយក្រសួងកសិកម្ម ដែលជាក្រសួងសាមី មិនមានអ្វីច្បាស់លាស់សោះ ពោលគឺអ្វីៗ ធ្វើទៅបានតាមរយៈបរទេសជួយតែប៉ុណ្ណោះ ហើយកន្លងមកធ្វើបានខ្លះ ជាពិសេសតែស្រូវមួយមុខគត់ដែលធ្វើទៅបាន ក្រៅពីនោះមិនមានអ្វីជាដុំកំភួនឡើយ។* កសិករធ្វើស្រែប្រឈមមុខនឹងការធ្លាក់ចុះនៃប្រាក់ចំណូលនៅអំឡុងពេលនៃការសង្កេត។ សមាគមអាដហុកបានរកឃើញថា គ្រួសារធ្វើស្រែចំការប្រមាណ៦០% រកចំណូលបានតិចជាង ៣០ដុល្លារអាមេរិកក្នុង១ខែ។ មិនមានការធ្វើអន្តរាគមន៍ ពីសំណាក់រាជរដ្ឋាភិបាលក្នុងការជួយប្រជាជនទាំងនេះទៅលើការកើនឡើងនៃថ្លៃទំនិញ និងការគ្មានការងារធ្វើឡើយ។

សមាគមអាដហុកបានទទួលយ៉ាងហោចណាស់ ករណីចំនួន៧ ស្តីពីការស្លាប់ដោយអត់ឃ្លាននៅក្នុងខេត្តកំពង់ស្ពឺ កំពត និងកណ្តាល។ *"ក្រៅពីនេះ របាយការណ៍ស្ទង់មតិមួយបានបង្ហាញថា ការស្លាប់ដោយអត់ឃ្លានបានកើតឡើងនៅក្នុងភូមិចំនួន ២២% ជាមធ្យម ហើយភូមិខ្លះនៅក្នុងខេត្តកំពង់ឆ្នាំងមានចំនួនខ្ពស់រហូតដល់៦៥% "នៅគ្រប់ករណីទាំងអស់ ជនរងគ្រោះ និងគ្រួសាររបស់ពួកគេមិនមានដីសម្រាប់ធ្វើស្រែចំការ... ប្រាក់ចំណូលរបស់ជនរងគ្រោះទាំងនោះមានកម្រិតទាបយ៉ាងខ្លាំង ពោលគឺទាបជាងកម្រិតចាំបាច់សម្រាប់ការរស់រានមានជីវិតបាន"* ។ របាយការណ៍ជាផ្លូវការមួយនៅខែកុម្ភៈ ឆ្នាំ ២០០៥ បានបង្ហាញថា អ្នកភូមិចំនួន១០-២០% (ប្រមាណ២.០០០ គ្រួសារ) នៅស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរនៃគ្រោះអត់ឃ្លាន។ ការនាំចេញស្រូវនៅរក្សាបរិមាណថេរ ប៉ុន្តែមានកម្រិតទាប ហើយការនាំចេញត្រីបានថយចុះយ៉ាងខ្លាំង (ប្រមាណ ៦៦% ដែលមានទឹកប្រាក់ចំនួន ៣,២ លានដុល្លារអាមេរិក) (វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ២០០៥កខ)។

រាជរដ្ឋាភិបាលមិនបានលើកស្ទួយលទ្ធភាពងាយស្រួលចំពោះហិរញ្ញវត្ថុនៅតំបន់ជនបទ និងបានផ្តល់ការគាំទ្រតិចតួចប៉ុណ្ណោះដល់តំបន់ដាច់ស្រយាល។ អសន្តិសុខស្បៀង និងកង្វះអាហារូបត្ថម្ភនៅបន្តជាបញ្ហា។ យោងតាមវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា *"ស្ទើរគ្រប់តំបន់ទាំងអស់ដែលត្រូវប្រើប្រាស់សម្រាប់ការដាំដុះ ត្រូវបានអង្គភាពឯកជនយកជាកម្មសិទ្ធិផ្ទាល់ខ្លួន និងមានតម្លៃថ្លៃណាស់សម្រាប់ការវិនិយោគ។ អ្នកមានមួយចំនួនតូចជាម្ចាស់លើដីស្រែមួយចំនួនធំ។ កង្វះឥណទាននាំឱ្យកសិករលក់ដីរបស់ពួកគាត់ជារឿយៗ...។ បញ្ហានេះ នាំឱ្យមានភាពគ្មានដីធ្លីកើនឡើង។ "ទំហំដី ដែលអាចដាំដំណាំបាន និងដែលមានប្រព័ន្ធធារាសាស្ត្រនៅក្នុងប្រទេសកម្ពុជា មានចំនួន៧% នៅក្នុងឆ្នាំ២០០២ ដែលជាចំនួនតិចជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍* (ធនាគារពិភពលោក ២០០៦)។

សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឆ្នាំ២០០៤ បញ្ជាក់ថា *"កសិករកម្ពុជាមិនអាចធ្វើការប្រកួតប្រជែងបានទេ ពីព្រោះពួកគេទទួលបានបច្ចេកទេសគ្រាប់ពូជ ប្រព័ន្ធធារាសាស្ត្រ និងគ្រឿងបរិក្ខារ ដទៃទៀតមានកម្រិត យ៉ាងខ្លាំង។ លើសពីនេះទៅទៀត ពួកគេមិនបានរៀបចំបានស្រួលបួលនោះទេ"*។ គ្មានរបាយការណ៍អំពីអន្តរាគមន៍របស់រាជរដ្ឋាភិបាល នៅក្នុងការជួយកសិករ ដោយផ្តល់នូវឧបត្ថម្ភធន និងផែនការធ្វើអន្តរាគមន៍អ្វីឡើយ។ ឧបសគ្គដែលរារាំងដល់ការ

ចូលទីផ្សារ គឺជាការប្រឈមមុខចំពោះការបែងចែកដល់កសិករនូវបរិក្ខារ គ្រាប់ពូជនានា និងជី: *"កង្វះលទ្ធភាពទទួលបានព័ត៌មានបច្ចេកទេស និងសំភារៈវត្ថុធាតុដើម សំរាប់កសិកម្ម ជាពិសេស កូនជ្រូក គ្រាប់ពូជ កូនដំណាំ សំភារៈតូចៗ និងព័ត៌មានទីផ្សារ បានដាក់ជាឧបសគ្គក្នុងការធ្វើកសិកម្មចំរុះមុខ និងការអភិវឌ្ឍលើកសិកម្មគ្រួសារដែលមានទីផ្សារទទួលទិញ"* (សេដាក ២០០៦)។ *"ឥណទានជនបទត្រូវបានពង្រីក ប៉ុន្តែអត្រាការប្រាក់នៅតែខ្ពស់យ៉ាងខ្លាំង ហើយតម្រូវការនូវឥណទាន មានគម្លាតឆ្ងាយពីការផ្គត់ផ្គង់ឥណទាន"* (បណ្ឌិត **ហង់ ជួនណារ៉ុន** ២០០៦)។ លោក **ខួច សេង** បានមានប្រសាសន៍ថា ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនទាន់មានគោលនយោបាយណាមួយ ដែលផ្ដល់ការបណ្ដុះបណ្ដាលដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីផ្ដល់អំណាចឱ្យពួកគេ នៅក្នុងការផ្ទេរចំណេះដឹង និងចំណេះធ្វើទៅឱ្យកសិករនៅឡើយ។

*"អត្រានៃភាពក្រីក្រ នៅតែមានកម្រិតខ្ពស់នៅតាមតំបន់ដាច់ស្រយាល ដោយហេតុថាការប្រើប្រាស់ផ្លូវថ្នល់ ទីផ្សារ និងសេវាផ្សេងៗ នៅមានកម្រិត... ដោយមិនមានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចគ្រប់គ្រាន់ ... ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល"* (ធនាគារពិភពលោក ២០០៦ ខ)។ ពុំមានរបាយការណ៍ស្ដីពីចលនាភូមិមួយ ផលិតផលមួយរបស់រាជរដ្ឋាភិបាលឡើយ។

នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ការកាប់បំផ្លាញព្រៃឈើបានកើនឡើង ដែលមានការប៉ះពាល់ខ្លាំង ដល់តំបន់មានមនុស្សរស់នៅច្រើន។ របាយការណ៍បានបញ្ជាក់ថា វិស័យព្រៃឈើចូលរួមចំណែកតែ២,១%ប៉ុណ្ណោះ ទៅក្នុង ផសស ទោះបីជារបាយ-ការណ៍នេះ មិនបានផ្ដល់ព័ត៌មានពិស្ដារអំពីការកាប់ឈើខុសច្បាប់ក៏ដោយ (ធនាគារពិភពលោក ២០០៦ ខ)។ របាយការណ៍បានលើកឡើងថា អត្រារីកចម្រើនប្រចាំឆ្នាំដែលមានចំនួន ៣,៩% នៅក្នុងទសវត្សមុនបានធ្លាក់ចុះ។ ចំណែកនៅក្នុងឆ្នាំ១៩៩៤ និង១៩៩៧ មានការរីកចម្រើនខ្ពស់ជាង។ ចាប់ពីពេលនោះមក អនុវិស័យនេះបានធ្លាក់ចុះយ៉ាងឆាប់រហ័ស ក្នុងចំនួនជាមធ្យម ៧%ក្នុង១ឆ្នាំ ដែលបណ្ដាលមក ពីការកាប់បំផ្លាញព្រៃឈើ ការគ្រប់គ្រងមិនបានល្អលើសម្បទានព្រៃឈើ ហើយនៅពេលថ្មីៗនេះ មានការបញ្ឈប់ជាបណ្ដោះអាសន្នលើអាជីវកម្មព្រៃឈើ។

ទោះបីជាមានរបាយការណ៍ជាច្រើនអំពីផ្នែកហេដ្ឋារចនាសម្ព័ន្ធនេះពីក្រសួងពាក់ព័ន្ធបង្ហាញថា សកម្មភាព និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក៏ដោយ ក៏របាយការណ៍ឯករាជ្យនានា បានវាយតម្លៃថា ហេដ្ឋារចនាសម្ព័ន្ធនៅមានលក្ខណៈខ្សោយ ក៏រិតហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជា គឺទាបបំផុតនៅអាស៊ីអាគ្នេយ៍ ដែលធ្វើឱ្យថ្លៃដើមផលិតផលខ្ពស់ គុណភាពសេវាអន់ និងកង្វះលទ្ធភាពនាំផលិតផលទៅកាន់ទីផ្សារ។ ធនាគារពិភពលោក (២០០៦ ខ) ក៏បានបញ្ជាក់ផងដែរថាប្រទេសកម្ពុជាមានការអភិវឌ្ឍយឺតលើបណ្ដាញផ្លូវថ្នល់ *"អត្រានៃអ្នកក្រីក្រមានសភាពខ្ពស់នៅតំបន់ដាច់ស្រយាលដោយសារមានការកម្រិតដល់ការប្រើប្រាស់ផ្លូវថ្នល់ ទីផ្សារ និងសេវាកម្មផ្សេងៗ"*។ នៅតែមានការខ្វះខាតទឹកស្អាត និងសុវត្ថិភាពទឹកជាពិសេស នៅឯជនបទដាច់ស្រយាល (ធនាគារពិភពលោក ២០០៦)។ ប្រហែលជា២៥%នៃផ្ទះនៅតាមជនបទអាចមានទឹកស្អាតសំរាប់បរិភោគ និងប្រហែលជាមានតែ១០% ប៉ុណ្ណោះដែលអាចទទួលបាននូវមធ្យោបាយងាយស្រួល និងអនាម័យ។

មានតម្រូវការឱ្យមានការលើកស្ទួយបន្ថែមទៀតដល់ផ្នែកឯកជនក្នុងវិស័យពាណិជ្ជកម្ម និងដើម្បីរក្សា និងពង្រីកទីផ្សារក្នុងស្រុក និងបរទេស។ ការលើកស្ទួយបន្ថែមទៀតក៏ចាំបាច់ផងដែរនៅក្នុងវិស័យទេសចរណ៍។ ធនាគារពិភពលោកបានបញ្ជាក់អំពីការរាំងស្ទះចំពោះគាំពារដល់ការរីកលូតលាស់ និងការងារដែលជាលទ្ធផលពីអភិបាលកិច្ចទន់ខ្សោយ ការិយាធិបតេយ្យ អំពើពុករលួយ កង្វះសមត្ថភាពគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុ និងការចំណាយខ្ពស់ដោយស្ថាប័នទាំងនោះ។ ដូចគ្នាដែរ ក៏មានការខ្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជាការដឹកជញ្ជូន ថាមពល ធនធានមនុស្ស និងជំនាញ និងការទទួលបានព័ត៌មាន ពីការប្រើប្រាស់ដីធ្លី និងទីផ្សារប្រកួតប្រជែង។

លោក **ម៉ឹង សុន** ប្រធាន ក្រុមហ៊ុនទេសចរណ៍ អ៊ីរ៉ាស៊ីត្រាវ៉ែល និងជាអនុប្រធាន សភាពាណិជ្ជកម្មប្រចាំខេត្តសៀមរាប បាននិយាយថា គ្មានការកើនឡើងចំនួនរមណីយដ្ឋានទេសចរណ៍ទេ។ ជាក់ស្ដែង រមណីយដ្ឋានទេសចរណ៍ធម្មជាតិ ដែលមានពីមុនត្រូវបានបំផ្លិចបំផ្លាញ ដោយសារការកាប់ព្រៃឈើខុសច្បាប់ដែលធ្វើឱ្យសត្វព្រៃរត់ចេញអស់។ លើសពីនេះទៅ ទៀត ទឹករីងស្ងួត និងទីតាំងដទៃទៀតត្រូវបំផ្លាញ ដោយសារតែគ្មានការថែរក្សាការពារ ដូចជា ក្បាលស្ពាន នៅខេត្តសៀមរាប ដែលក្បាច់ចម្លាក់នៅក្រោមទឹកត្រូវបានគេលួច។ ការអភិវឌ្ឍខ្លះ នៅមិនទាន់ស្របនឹងប្រពៃណីខ្មែរនៅឡើយដូចជា នៅភ្នំសន្ទុកក្នុងខេត្តកំពង់ធំ

ប្រាសាទដែលគេលាបពណ៌មិនដូចរបៀបខ្មែរ ។ លោក **ហូ វ៉ាន់ឌី** ប្រធានសមាគមកម្ពុជានៃភ្នាក់ងារទេសចរណ៍ បាននិយាយថា ការវិនិយោគឯកជននៅក្នុងវិស័យទេសចរណ៍ មិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ ដោយសារតែមាន គោលនយោបាយមិនច្បាស់លាស់រវាងរដ្ឋាភិបាល និងអ្នកវិនិយោគឯកជន ។ លោក **ហូ វ៉ាន់ឌី** បានពន្យល់ថា ការផ្សព្វផ្សាយរបស់រដ្ឋាភិបាលមិនមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់នៅឡើយ ។ ការផ្សព្វផ្សាយអំពីទេសចរណ៍នៅប្រទេស កម្ពុជាមានលក្ខណៈ ខ្សោយណាស់ បើប្រៀបធៀបនឹងប្រទេសដទៃទៀតនៅក្នុងតំបន់ ។ ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធព័ត៌មានវិទ្យាមានលក្ខណៈ មិនទូលំទូលាយគ្រប់គ្រាន់ទេ ហើយថ្វីបើព័ត៌មានអេឡិចត្រូនិចមាននៅក្នុងគេហទំព័ររបស់ក្រសួងទេសចរណ៍ក៏ដោយ ក៏ព័ត៌មានទាំងនោះមិនទាន់ហេតុការណ៍ ឬមិនគ្រប់គ្រាន់ឡើយ ។

## III- ផ្នែកសង្គមកិច្ចៈ អប់រំ សុខភាព និងវប្បធម៌

ចំណែកផ្នែកសង្គមកិច្ច *ការបំពេញការងាររបស់រាជរដ្ឋាភិបាលមានលក្ខណៈមធ្យម ។* ស្ទើរតែទាំងអស់នៃសូចនាករដែលបានសន្យាត្រូវបានបំពេញដោយផ្នែកខ្លះប៉ុណ្ណោះ ។ ភាគច្រើននៃការងារដែលបានបំពេញ គឺចិតក្រោមជំនួយគាំទ្រពីម្ចាស់ជំនួយ និងសហគមន៍អន្តរជាតិ ។

ការសន្យាសំខាន់ៗចំនួនពីរត្រូវបានបំពេញនោះគឺ ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែរក្សាតំបន់អភិរក្សទុកជាសម្បត្តិទ្រព្យជាតិ ។ មានការគោរពសេរីភាពនៃជំនឿ និងការលើកស្ទួយសាសនា បើទោះបីជាមានកង្វះខាតការងារស្រាវជ្រាវនៅក្នុងវិស័យនេះក៏ដោយ ។

ចំពោះវិស័យអប់រំ រាជរដ្ឋាភិបាលបានបំពេញការសន្យារបស់ខ្លួនតែផ្នែកខ្លះប៉ុណ្ណោះស្តីពីការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពធនធានមនុស្ស និងការផ្តល់នូវការអប់រំសំរាប់ទាំងអស់គ្នា ។ វាជាការចាំបាច់ក្នុងការបង្កើនបន្ថែមទៀតនូវការពង្រឹងភាពជាដៃគូជាមួយនឹងផ្នែកឯកជន ព្រមទាំងការបង្កើនថវិកាចំណាយ ។ ការខិតខំបន្ថែមទៀតក៏ចាំបាច់ផងដែរ សំរាប់កំណែទម្រង់កម្មវិធីសិក្សា និងការកសាងសាលានៅតាមតំបន់ជនបទ និងការជំរុញកម្មវិធីអក្ខរកម្ម និងការអប់រំក្រៅប្រព័ន្ធ ។ មានការបង្ហាញថា សមត្ថភាពរបស់គ្រូបង្រៀននៅមានកម្រិតទាបនៅឡើយ ហើយទាមទារឱ្យមានការពង្រឹងបន្ថែមទៀតនៅក្នុងវិស័យនេះ ( អង្គការភាពជាដៃគូនៅក្នុងការអប់រំដោយអង្គការមិនមែនរដ្ឋាភិបាល ២០០៦ : ៥១) បញ្ហាផ្សេងៗទៀតនៅក្នុងវិស័យនេះ ត្រូវបានរកឃើញដោយសមាគមអាដហុក ដូចជាសាលានៅឆ្ងាយពីផ្ទះរបស់កុមារទាំងនោះ អសមភាពយេនឌ័រ កង្វះខាតការបណ្តុះបណ្តាលបែបសង្គមដល់ឪពុកម្តាយអំពីសារៈសំខាន់នៃការអប់រំ តម្រូវការឱ្យបង់ថ្លៃឈ្នួលសិក្សាខុសច្បាប់ទៅអ្នកគ្រូ លោកគ្រូ ថ្នាក់រៀនមានសិស្សច្រើន និងខ្វះគ្រូបង្រៀន ។ អង្គការភាពជាដៃគូ នៅក្នុងការអប់រំដោយអង្គការមិនមែនរដ្ឋាភិបាល ថ្លែងថា : *"និស្សិត និងមាតាបិតាបង់ថ្លៃសិក្សា ដែលពិបាករកបានមក ដើម្បីគុណភាព និងតម្លៃមិនច្បាស់លាស់ ហើយវិទ្យាស្ថានឧត្តមសិក្សាសាធារណៈនៅតែមិនទទួលបានការគាំទ្រពីរដ្ឋាភិបាល និងតម្រូវឱ្យមាននិស្សិតមិនបង់ថ្លៃចំនួន ៥០%"* ។ សមាគមអាដហុក (២០០៦ : ៤០) បានបញ្ជាក់ថា *"កត្តាចុងក្រោយនេះ គឺបញ្ហាបៀវត្សរ៍មិនសមរម្យសំរាប់ធ្វើឱ្យជីវភាពរបស់គ្រូប្រកបដោយភាពថ្លៃថ្នូរ ហើយបានជំរុញឱ្យពួកគាត់ស្វែងរករបរបន្ថែមទៀត ដើម្បីរកប្រាក់យកមកបង្គ្រប់ការចិញ្ចឹមជីវិត ជាហេតុនាំឱ្យពួកគាត់មិនមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើការសិក្សា និងស្រាវជ្រាវបន្ថែមទៅលើមេរៀនថ្មីៗសំរាប់យកមកបង្រៀនកូនសិស្សឱ្យបានល្អិតល្អន់ឡើយ"* ។ *ការសម្ភាសន៍ជាមួយនឹងគ្រូបង្រៀនមួយចំនួននៅតាមសាលាខ្លះនៅទីក្រុងភ្នំពេញបានឱ្យដឹងថា ថ្នាក់រៀនខ្លះមានចំនួនសិស្ស-និស្សិតពី៧៥-៨០នាក់"* ( អាដហុក ២០០៦) ។ រាជរដ្ឋាភិបាលមិនទាន់បានបញ្ជាក់ផែនការជា យុទ្ធសាស្ត្រឱ្យបានច្បាស់លាស់ស្តីពីយុវជននៅឡើយទេ ។

ទន្ទឹមគ្នានេះផងដែរ វិស័យសុខាភិបាល មានលក្ខណៈខ្សោយ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ជាពិសេស ចំពោះការចូលរួមពីផ្នែកឯកជន ចំពោះការអនុវត្តកម្មវិធីបង្ការ និងព្យាបាលនូវជម្ងឺឆ្លងនានា ការគាំពារមាតា និងទារក ការធ្វើឱ្យប្រសើរឡើងនូវសេវាសង្គ្រោះបន្ទាន់ ព្រមទាំងការអប់រំស្តីពីអនាម័យ និងសុខភាពឱ្យកាន់តែទូលំទូលាយ ការផ្តល់ឱកាសដល់អ្នកក្រីក្រឱ្យទទួលបាននូវសេវាពិនិត្យសុខភាពដោយឥតគិតថ្លៃ និងបង្កើនគុណភាពមន្ត្រីសុខាភិបាលដែលមានសមត្ថភាព ។ របាយការណ៍របស់រាជរដ្ឋាភិបាល ( ក្រសួងសុខាភិបាល ២០០៥ ខ) បានបង្ហាញថា ការចាក់ថ្នាំបង្ការ ជម្ងឺរបេង បានត្រឹម

តែចំនួន៦១% នៃក្រុមគោលដៅប៉ុណ្ណោះ (គោលដៅគឺត្រូវសម្រេចឱ្យបានចំនួន៦៦%)។ ទោះបីជាមានការកើនឡើងនូវចំនួនមណ្ឌលសុខភាព មួយភាគបួននៃចំនួនមណ្ឌលទាំងនេះ មិនមានឆ្មបឡើយ (សម្តេច **ហ៊ុន សែន** ២០០៦ : ៣៣)។ ធនាគារពិភពលោកបានបន្តបង្ហាញថា អត្រាមរណភាពពេលសម្រាលកូននៅតែមានកម្រិតខ្ពស់ ពោលគឺចំនួន៤៣៧នាក់ ក្នុងចំណោម ១០០.០០០ នាក់ នៅឆ្នាំ២០០៤ (ក្រសួងសុខាភិបាល ២០០៦ : ៣៣)។ *"ទោះបីជាសេវាសុខភាពមានលក្ខណៈអំណោយផលជាស្រេចក៏ដោយ តែការផ្តល់សេវាដល់អ្នកក្រីក្រនៅតែមិនបានជិតដល់ ដោយមន្ត្រីសុខាភិបាលគិតថាអ្នកក្រមិនមានលទ្ធភាពបង់ថ្លៃព្យាបាល* (មេឌីខេម ២០០៦ : ៥៥)។ សមាគមអាដហុក បានកត់សម្គាល់ថា *"បញ្ហានៅតែកើតមានដដែលៗដូចកាលពីឆ្នាំកន្លងៗទៅដែរ គឺការទារប្រាក់ក្រៅផ្លូវការ មន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅឆ្ងាយពីកន្លែងដែលប្រជាពលរដ្ឋរស់នៅ"*។ (អាដហុក ២០០៦ : ៤៣)។ របាយការណ៍របស់អង្គការ Action Aid (២០០៥) បានបង្ហាញថា មាន៩៦,២%នៃប្រជាជន មានជម្ងឺ ត្រូវតែបង់ថ្លៃព្យាបាលសម្រាប់ការព្យាបាលរបស់ខ្លួននៅមណ្ឌលសុខភាព ហើយចំនួន៨៨,២% ក្នុងចំណោមពួកគេយល់ថា មិនអាចបង់ថ្លៃសេវានេះបានឡើយ។ ផ្អែកលើការសម្ភាសន៍មេភូមិនៅភូមិចំនួន ៩០០ ដែលធ្វើឡើងដោយទីភ្នាក់ងារស្រាវជ្រាវសេដ្ឋកិច្ចសង្គមកម្ពុជា នៅឆ្នាំ២០០៤ នូវសំណួរថាតើមានការធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាកម្មសុខភាពនៅក្នុងភូមិរបស់ពួកគេដែរឬទេនោះ មានមេភូមិចំនួនតែ៥៦%ប៉ុណ្ណោះបានផ្តល់ចម្លើយគួរជាទីពេញចិត្ត ហើយការកាត់បន្ថយគុណភាពនៃការថែទាំត្រូវបានកត់សម្គាល់ថាមានចំនួន ៦% ជាទូទៅ។ យោងទៅតាមការសម្ភាសន៍ទាំងនេះ បញ្ហាកង្វះឱសថត្រូវបានរកឃើញថាជាកត្តាសំខាន់ បំផុតតែមួយគត់ (ធនាគារពិភពលោក ២០០៦ ខ)។ *"ចំនួនអ្នកផ្តល់សេវាដែលបានបណ្តុះបណ្តាលត្រឹមត្រូវដែលបញ្ជូននិងចាត់តាំងមិនបានសមស្របនាំឱ្យមានការកង្វះខាតបុគ្គលិក និងវត្តមាននៅមូលដ្ឋានសុខាភិបាល* (មេឌីខេម ២០០៦ : ៥៥)។

លើសពីនេះទៅទៀត រាជរដ្ឋាភិបាល បានបំពេញតែផ្នែកខ្លះប៉ុណ្ណោះនៃការសន្យារបស់ខ្លួនស្តីពីការបង្កើនការវិនិយោគលើវិស័យសង្គមកិច្ច ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងការជំរុញការបង្កើនការងារ។ មានតម្រូវការបន្ថែមផ្សេងទៀត ក្នុងការពង្រឹងតួនាទី និងស្ថានភាពសង្គមរបស់ស្ត្រី និងការលើកស្ទួយសិទ្ធិស្ត្រី និងការការពារកុមារ។

ធនាគារពិភពលោកបានកត់សម្គាល់ដែរថា កាលានុវត្តភាពរបស់វិស័យឯកជនត្រូវបានដាក់កំហិតចំពោះផ្តល់ឱ្យការងារមានកំណើនពិសេសដោយសារតែអំពើពុករលួយ។ មាន *"ការទទួលបានមានកំណត់ចំពោះការងារ ឬប្រាក់ចំណូលសម្រាប់ប្រជាជនក្រីក្រ"*។ សមាគមអាដហុក (២០០៦ : **៣៤ និង ២១**) បានថ្លែងថា *"មិនមានអន្តរាគមន៍ពីរដ្ឋាភិបាលក្នុងការជួយប្រជាជនក្រីក្រទាំងនោះ ទន្ទឹមនឹងថ្លៃទំនិញ និងភាពគ្មានការងារធ្វើកើនឡើង"* ហើយថា ស្ត្រីនៅតែមានលទ្ធភាពតិចតួច ក្នុងការទទួលបានការងារធ្វើមានកម្រៃ។ ធនាគារពិភពលោក (២០០៦ ខ) ថ្លែងថា *"ប្រសិនបើមូលដ្ឋានអភិបាលកិច្ចសេដ្ឋកិច្ចមិនមានទេនោះ ហើយទីផ្សារមិនអាចឆ្លើយតបនឹងការផ្គត់ផ្គង់ការងារដែលកើនឡើងនេះទេ និកម្មភាពរបស់យុវជន និងភាពក្រីក្រដែលនៅជាមួយនេះ ទំនងជាក្លាយជាបញ្ហាធ្ងន់ធ្ងរ។"*

ការជំរុញការអនុវត្តច្បាប់ការងារមានលក្ខណៈខ្សោយ *"កិច្ចប្រឹងប្រែងជំរុញការអនុវត្តរបស់រដ្ឋាភិបាលត្រូវបានរាំងស្ទះថែមទៀត ដោយកង្វះឆន្ទៈនយោបាយ ហើយដោយទំនាក់ទំនងនយោបាយ និងហិរញ្ញវត្ថុ ដោយភ័ន្តច្រឡំគ្នាជាមួយនឹងក្រុមនិយោជក និងមេដឹកនាំសហជីព។ រដ្ឋាភិបាលក៏ទទួលរងគ្រោះផងដែរពីកង្វះធនធាន ដែលរួមមានអ្នកធ្វើអធិការកិច្ចការងារមានបទពិសោធន៍ និងទទួលការបណ្តុះបណ្តាលមួយផ្នែកដោយសារតែរដ្ឋមិនបានផ្តល់ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ដល់បុគ្គលិក។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសម្រេចចិត្តជារឿយៗ ផ្តល់ការគាំទ្រចំពោះនិយោជិក ប៉ុន្តែក្រសួង កម្រនឹងប្រើប្រាស់សមត្ថកិច្ចតាមផ្លូវច្បាប់របស់ខ្លួន ដើម្បីដាក់ទោសទណ្ឌដល់និយោជក ដែលមិនគោរពតាមបទបញ្ជារបស់ ខ្លួន។"* មានការរាយការណ៍ផងដែរអំពីការពន្យាពេលបែបការិយាធិបតេយ្យនៅក្នុងការចុះឈ្មោះសហជីព។

ដោយផ្អែកលើការវាយតម្លៃយេនឌ័រប្រទេសកម្ពុជាមានសមភាពយេនឌ័រទាបជាងគេបំផុតនៅទ្វីបអាស៊ី ដូចដែលបានបង្ហាញដោយអត្រានៃការអភិវឌ្ឍ (០,៥៩៧) និងការប្រគល់អំណាចយេនឌ័រ (០,៣៦៤) (ធនាគារពិភពលោក២០០៥:គ)។

អ្នកតំណាងជាប់ឆ្នោតជាស្ត្រី នៅក្នុងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ មានចំនួន ៨,៥% និងសមាជិកសភា មានចំនួន ១២,២%។ យេនឌ័រ និងបណ្តាញអភិវឌ្ឍន៍ (២០០៦)ឱ្យដឹងថា *"កង្វះការទទួលបានជាសាធារណៈនូវការអប់រំច្បាប់ គឺជាបញ្ហា*

*ធ្ងន់ធ្ងរមួយនៅក្នុងប្រទេសនេះ ។ ចំនួនប្រជាពលរដ្ឋភាគច្រើន ជាពិសេសចំនួនស្ត្រីក្រីក្រនៅជនបទ មិនទទួលបានការអប់រំ និងចំណេះ ដឹងផ្នែកច្បាប់ឡើយ ដែលធ្វើឱ្យពួកគាត់ងាយរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស និងការកេងប្រវ័ញ្ច ។*

របាយការណ៍មួយរបស់អង្គការជួយស្ត្រីមានវិបត្តិ (CWCCឆ្នាំ២០០៦) បានបង្ហាញថា ស្នាក់ការទាំងបីរបស់ខ្លួនបានទទួលករណីចំនួន ១.២៦៤ ក្នុងចំណោមនោះ មានករណីហិង្សាចំនួន៩១០ ករណីរំលោភចំនួន១៦៣ និងករណីកេងប្រវ័ញ្ចផ្លូវភេទមានចំនួន១៩១ ។ លើសពីនេះទៀត ក្រសួងកិច្ចការនារីបានឱ្យដឹងថា ២៥%នៃស្ត្រីកម្ពុជាបានទទួលរងអំពើហិង្សាក្នុងគ្រួសារ ។ ក្រសួងកិច្ចការនារី (ឆ្នាំ២០០៥) បានធ្វើសម្ភាសន៍ប្រជាជនចំនួន៣.០០០នាក់ រស់នៅក្នុងខេត្តចំនួន១៣ ស្តីពីឥរិយាបថពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារ ។ ៨០%នៃស្ត្រីដែលត្រូវបានធ្វើការស្ទាបស្ទង់បាននិយាយថា ពួកគេបានដឹងអំពីប្តីដែលប្រើអំពើហិង្សាលើរាងកាយទៅលើប្រពន្ធរបស់ខ្លួន ហើយចំនួនស្ត្រីច្រើន ជាង១ ក្នុងចំណោម៤នាក់ បាននិយាយថា ពួកគេបានធ្លាប់ឆ្លងកាត់អំពើហិង្សាក្នុងគ្រួសារ ។

រហូតមកដល់ពាក់កណ្តាលឆ្នាំ ២០០៥ របាយការណ៍ជាច្រើនបានចង្អុលបង្ហាញពីភាពងាយរងគ្រោះធ្ងន់ធ្ងរដល់កុមារ ។ នៅពេញមួយឆ្នាំ២០០៥តាមការរាយការណ៍របស់សមាគមសិទ្ធិមនុស្ស អាដហុក ភាគច្រើននៃជនរងគ្រោះករណីរំលោភផ្លូវភេទគឺជាកុមារ ។ ក្នុង ៣៩០ករណី **ជនរងគ្រោះជាកុមារ**មានចំនួន២៨៤នាក់ ហើយមាន៩២នាក់ ស្មើនឹង ២៤% ជាជនរងគ្រោះមានអាយុក្រោម១០ឆ្នាំ និងជនរងគ្រោះចំនួន១៩២នាក់ ស្មើនឹង៥៣% មានអាយុចាប់ពី១១ ដល់ ១៧ឆ្នាំ ។ មានតែ៩២នាក់ ស្មើនឹង ២៣% ដែលជាជនរងគ្រោះស្ត្រីភេទ មានអាយុចាប់ពី១៨ឆ្នាំ ។ របាយការណ៍មួយរបស់អង្គការប្រឆាំងនឹងការជួញដូរមនុស្ស និងការការពារអនីតិជនបានឱ្យដឹងថា នៅឆ្នាំ២០០៤មានករណីឧក្រិដ្ឋលើផ្លូវភេទចំនួន៥៦៣ករណី ដែលប៉ូលីស បានធ្វើការស៊ើបអង្កេតចំពោះជនរងគ្រោះចំនួន៦៣៦នាក់ រួមទាំង៤៣៣នាក់ ស្មើនឹង៦៨%ជាកុមារ ។ នៅឆ្នាំ២០០៥ គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីកុមារ បានទទួលករណីរំលោភផ្លូវភេទចំនួន ១៣៩ករណី ដែលមានកុមារចំនួន១៤២ នាក់ ជាជនរងគ្រោះក្នុងនោះ៣២នាក់មានអាយុ៩ឆ្នាំ ៦៩នាក់មានអាយុពី១០ ទៅ១៤ឆ្នាំ និង៤១នាក់មានអាយុពី១៥ ទៅ១៧ឆ្នាំ ។ *"ការស្រាវជ្រាវធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៅឆ្នាំ២០០៣ បង្ហាញថា មានកុមារចំនួន ២៧.៩៥០នាក់ កំពុងធ្វើការជាកម្មករស៊ីឈ្នួលនៅតាមផ្ទះ នៅរាជធានីភ្នំពេញ ។ កុមារទាំងនេះមិនមានឱកាសរៀនសូត្រ ហើយភាគច្រើននៃពួកគេកំពុងជួបប្រទះនូវការកេងប្រវ័ញ្ច និងការរំលោភបំពានទាំងផ្លូវកាយ និងផ្លូវចិត្តជារៀងរាល់ថ្ងៃ ។ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នមួយចំនួនរបស់រដ្ឋាភិបាលកំពុងធ្វើការងារលើបញ្ហានេះ ប៉ុន្តែពួកគេមិនមានបទពិសោធន៍គ្រប់គ្រាន់ ហើយជួនកាលមានការសម្របសម្រួលមានកម្រិតពីសំណាក់អាជ្ញាធរពាក់ព័ន្ធ និងម្ចាស់ផ្ទះ"* ។

រាជរដ្ឋាភិបាលកម្ពុជា **សម្រេចបានសមិទ្ធិផលមួយចំនួនលើការលើកស្ទួយវិស័យវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់** ដោយអនុវត្តបន្តការងារពីអាណត្តិមុនមកក្នុងក៏រិតមធ្យម ។ យោងតាមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសមិទ្ធិផល សកម្មភាពមួយចំនួននៅក្នុងអំឡុងពេលសង្កេតនេះ ។ មន្ត្រីជំនាញបានធ្វើទស្សនកិច្ចយ៉ាងទៀងទាត់ និងផ្តល់យោបល់ដល់សហគ្រិនដែលរកទទួលទាននឹងសិប្បកម្ម និងវត្ថុសិល្បៈ ។ ពិធីបុណ្យភាពយន្តខ្មែរ ត្រូវបានប្រារព្ធឡើងជាមួយនឹងក្រុមហ៊ុនផលិតកម្មភាពយន្ត ចំនួន ១៣បាន ដាក់ចូលប្រកួតនូវភាពយន្តចំនួន ២២រឿង ។ រាជរដ្ឋាភិបាលកម្ពុជា ក៏អនុញ្ញាតឱ្យមានការប្រារព្ធខួបឆ្នាំទី ១០ នៃកំណើតខ្លែងខ្មែរជាថ្មី នៅថ្ងៃទី ១០ តុលា ២០០៤ ។ មានព្រឹត្តិការណ៍វប្បធម៌ និងតន្ត្រីចំនួន ៤.៥៧៣លើក នៅក្នុងនោះពិធីចំនួន១០ ធ្វើនៅក្រៅប្រទេស ។ នៅឆ្នាំ២០០៥ គណៈប្រតិភូចំនួន ១១នាក់អញ្ជើញមកពីប្រទេសចំនួន១៥ សម្រាប់គម្រោងអភិវឌ្ឍន៍ វិស័យវប្បធម៌ និងអភិរក្ស ក្នុងខណៈពេលដែលគណៈប្រតិភូកម្ពុជាចំនួន៩៧ បានអញ្ជើញទៅវេទិកាអន្តរ-ជាតិ ហើយចំនួន១៧ នៃអង្គការទាំងនោះ ដែលបានចូលរួមសិក្ខាសាលានានា ផ្លាស់ប្តូរបទពិសោធន៍ ដែលទទួលបាននៅក្នុងវិស័យវប្បធម៌សិល្បៈ និងពិធីបុណ្យបង្ហោះខ្លែងខ្មែរ ។ តាមរយៈក្រសួងវប្បធម៌ និងក្រសួងទេសចរណ៍ វប្បធម៌ខ្មែរត្រូវបានផ្សព្វ-ផ្សាយ ទាំងនៅលើប្រព័ន្ធអេឡិចត្រូនិច និងបោះពុម្ពទាំងក្នុង និងក្រៅប្រទេស រួមទាំងប៉ុស្តិ៍ទូរទស្សន៍បណ្តាញព័ត៌មាន ខ្សែកាបស៊ីអ៊ិនអ៊ិន (CNN) ។ ក្រសួងវប្បធម៌បានផ្សព្វផ្សាយសេចក្តីប្រកាសជាបដា និងសន្លឹកក្រដាសផ្សព្វផ្សាយធំៗ នៅតាមខេត្ត-ក្រុងចំនួន ១៣ ហើយនិងផ្សព្វផ្សាយច្បាប់ស្តីពីការរក្សាសិទ្ធិ និងសិទ្ធិប្រហាក់ប្រហែលនៅក្នុងខេត្ត-ក្រុងចំនួន ១០ ។

**សិទ្ធិអប់រំ និងសកម្មភាពនៅមានក៏រិតមិនអាចទប់ទល់ទៅនឹងវប្បធម៌ពាលាអាវ៉ាសែ** ។ ឯកឧត្តម **សំរាំង កំសាន្ត** អនុ

រដ្ឋលេខាធិការក្រសួងវប្បធម៌ បានមានប្រសាសន៍ថា "**រាជរដ្ឋាភិបាលកម្ពុជាជាពិសេសក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជួបនឹងបញ្ហាប្រឈមច្រើន ចំពោះការហូរចូលនូវវប្បធម៌បរទេសពាលាអាវ៉ាសែ**"។

## IV- ការវិភាគ និងសេចក្តីសន្និដ្ឋាន

មានការពិចារណាច្រើនថែមទៀតដែលត្រូវផ្តល់ចំពោះសំណួរជាមូលដ្ឋានទូទៅអំពីប្រទេសកម្ពុជា និងដំណើរការវិវត្តន៍របស់ខ្លួនទៅជាប្រទេសសេដ្ឋកិច្ច និងប្រទេសប្រជាធិបតេយ្យទំនើប។

១. នៅឆ្នាំ២០០៦ តើប្រទេសកម្ពុជាបច្ចុប្បន្ន មានលក្ខណៈខិតឆ្ពោះទៅជិតឧត្តមគតិនេះ ជាងប្រទេសកម្ពុជានៅឆ្នាំ២០០៣ ឬចាប់តាំងពីឆ្នាំ១៩៩៣ នៅពេលដែលរដ្ឋធម្មនុញ្ញថ្មីត្រូវបានបង្កើត?

២. តើប្រទេសកម្ពុជាកំពុងដំណើរការទៅយ៉ាងដូចម្តេចខ្លះ នៅក្នុងក្រសែភ្នែករបស់ពិភពលោក? ថាតើជាប្រទេសមួយដែលចូលរួមយ៉ាងល្អជាមួយស្ថាប័នអន្តរជាតិនានា ពោលគឺដោយមានការស្វាគមន៍ និងការគោរព ឬក៏នៅតែត្រូវបានសំឡឹងមើលជាមួយនឹងភាពសង្ស័យ ហើយស្ថិតក្នុងដំណាក់កាលសាកល្បង?

៣. ក្នុងន័យធៀបនឹងរដ្ឋាភិបាលនៃប្រទេសផ្សេងៗទៀត តើរាជរដ្ឋាភិបាលកម្ពុជាកំពុងទទួលបានជោគជ័យក្នុងការធ្វើឱ្យប្រទេសជាតិក្លាយជាប្រទេសប្រសើរមួយ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបរបស់ខ្លួន ពោលគឺជាទីកន្លែងដែលសមភាពនៃកាលានុវត្តភាពកំពុងក្លាយជាការពិតសម្រាប់ស្ត្រី ជនក្រីក្រ និងក្រុមជនងាយរងគ្រោះដែរឬទេ?

៤. តើស្ថាប័នទាំងឡាយដែលជំរុញ និងការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជា ហើយដែលអនុញ្ញាតឱ្យមានការសម្រេចបានសេចក្តីប្រាថ្នារបស់ពួកគេ កំពុងធ្វើការយ៉ាងមានប្រសិទ្ធភាពឆ្ពោះទៅរកគោលដៅនេះដែរឬទេ?

៥. តើប្រទេសកម្ពុជាកាន់តែពឹងអាស្រ័យតិចតួចលើធនធានពីខាងក្រៅ ក្នុងការធ្វើឱ្យមានការរីកចម្រើនមែនឬទេ ជាមួយនឹងសូចនាករច្បាស់លាស់នៃសមត្ថភាពដែលកើនឡើង ដើម្បីចាត់ចែងការងារផ្ទាល់របស់ផងខ្លួនប្រកបដោយប្រសិទ្ធភាព?

របាយការណ៍នេះ ដែលជាការសង្កេតផ្ទាល់របស់ ខុមហ្វ្រែល និងរបស់ស្ថាប័នផ្សេងទៀត សូមបង្ហាញជូននូវការរកឃើញដូចខាងក្រោមនេះ ៖

១. ប្រទេសកម្ពុជា និងរាជរដ្ឋាភិបាល សម្រេចបាននូវការរីកចម្រើនដោយគ្មានការសង្ស័យ ប៉ុន្តែការរីកចម្រើននេះមិនមានការធានា ឬមានលក្ខណៈជាប់ជាប្រចាំឡើយ។ ការបញ្ចប់ជម្លោះរវាងភាគីនានា បានបង្កើនកម្រិតស្ថេរភាព ប៉ុន្តែនយោបាយនៅតែចរិកដោយការប្រជែងយកអំណាច ដែលមានទំនោរទៅរកការចាប់ផ្តើមជាថ្មី នូវជម្លោះប្រដាប់អាវុធ។ ការប្រជែងនេះរារាំងដល់ការចរចារវាងភាគីពាក់ព័ន្ធ ទៅលើបញ្ហាសំខាន់ៗរបស់ជាតិ ដែលនាំឱ្យមានជាសំណួរអំពីការប្តេជ្ញាចិត្តពិតប្រាកដចំពោះការប្រកាន់យកលទ្ធិប្រជាធិបតេយ្យ ដែលការសម្រេចចិត្តរបស់ប្រជាជនតាមរយៈប្រអប់ឆ្នោតដែលប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ និងនាំឱ្យមានការផ្ទេរអំណាចដោយសន្តិវិធី និងមានសណ្តាប់ធ្នាប់។ រាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចមិនទាន់បង្ហាញការតាំងចិត្តដាច់ខាតចំពោះដំណើរការប្រជាធិបតេយ្យ និងវិធានទាំងឡាយ ដែលធ្វើឱ្យប្រជាធិបតេយ្យ មានដំណើរការឡើយ ទោះបីជាពេលថ្មីៗនេះ មានការខិតជិតជាថ្មីទៀត ជាមួយនឹងមេដឹកនាំគណបក្សជំទាស់ក៏ដោយ។

២. កត្តានេះ រួមជាមួយនឹងការចងចាំដែលដក់ជាប់នឹងប្រវត្តិសាស្ត្រជូរចត់ថ្មីៗរបស់ប្រទេសកម្ពុជា ពន្យល់អំពីមូលហេតុ ដែលប្រទេសកម្ពុជាមិនទាន់ត្រូវបានទទួលស្គាល់ពេញលេញនៅលើឆាកអន្តរជាតិ បើទោះបីជាមានសំណល់នៃសុឆន្ទៈដោយគ្មានមន្ទិល និងការគាំទ្រជាបន្តពីសំណាក់ប្រទេសជាមិត្តភាគច្រើនក៏ដោយ។ ជាការពិតណាស់ ការណ៍នេះជួយដល់ប្រទេសកម្ពុជា ចាកចេញអំពីការមើលឃើញថា ជាប្រទេសមួយនៃចំណុចក្តៅរបស់ពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ ការវិនិច្ឆ័យអាស្រ័យលើកត្តាជាច្រើន និងផ្អែកលើការរីកចម្រើន

និងការធ្វើឱ្យ ប្រសើរឡើងជាប្រចាំ។ ប្រតិកម្មចំពោះព្រឹត្តិការណ៍ចម្បងៗក៏មានសារៈសំខាន់ដូចគ្នានេះផងដែរ។ របៀបដែល កម្ពុជានឹងធ្វើ ក្នុងតួនាទីទៅក្នុងការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហមនាពេលបន្តិចទៀតនេះ នឹងជាវិញ្ញាសាដ៏សំខាន់មួយ។ ពួកគេចាំបាច់ត្រូវដោះស្រាយភាពមន្ទិល ឈរលើអព្យាក្រឹត្យភាពប្រកបដោយវិជ្ជាជីវៈនិយម និងភាពស្មោះត្រង់ក្នុងចំណោមតួអង្គចូលរួមផ្សេងៗគ្នាច្រើននៅក្នុងដំណើរការក្ដីនោះ ហើយដើម្បីកំណត់ដំណើរការ ទាំងអស់នោះឱ្យប្រចក្យ ជាបទដ្ឋានគម្រូវសម្រាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ជាធម្មតាប្រចាំថ្ងៃ។

៣. ប្រទេសកម្ពុជា និងរាជរដ្ឋាភិបាល កំពុងធ្វើឱ្យមានការរីកចម្រើន សំដៅប្រែក្លាយប្រទេសឱ្យកាន់តែមានវិបុលភាព និងជាទីកន្លែងប្រសើរមួយសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន ប៉ុន្តែច្បាស់ណាស់ថា ភាពក្រីក្រនៅស្ថិតជាមួយប្រជាពលរដ្ឋចំនួនច្រើនជាងមួយភាគបី។ សម្ដេច ហ៊ុន សែន បានមានប្រសាសន៍ថា *"ប្រសិនបើប្រទេសកម្ពុជានឹងបន្តជាធម្មតាដូច្នេះ ប្រទេសនេះនឹងមិនអាចកាត់បន្ថយភាពក្រីក្របានពាក់កណ្ដាលឡើយ ប៉ុន្តែអាចនឹងសង្ឃឹមថា ឧប្បទ្ទេវហេតុភាពក្រីក្រនៅមានចំនួន ២៨% នៅឆ្នាំ ២០១៥"* ដូច្នេះ វានៅឆ្ងាយពីគោលដៅសហសវត្សរ៍ ដែលកំណត់កាត់បន្ថយភាពក្រីក្រចំនួនពាក់កណ្ដាល (ធនាគារពិភពលោក ឆ្នាំ២០០៤: *ចាប់យកឱកាសសកល : ការវាយតម្លៃបរិយាកាសវិនិយោគ និងយុទ្ធសាស្ត្រកំណែទម្រង់សម្រាប់ប្រទេសកម្ពុជា*)។ ការវិភាគលម្អិត បង្ហាញអំពីការរីកចម្រើនមិនស្របគ្នានៅក្នុងវិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងវិស័យអភិវឌ្ឍន៍ជនបទ។ល។ ហើយទាំងនេះទំនងជាជះឥទ្ធិពលលើការកាត់បន្ថយភាពក្រីក្រ។ ការពិនិត្យមើលស្ថានភាពរបស់ស្ត្រី និងជាពិសេសក្រុមជនងាយរងគ្រោះនានា បង្ហាញនូវគំរូស្រដៀងគ្នាមួយ ហើយកាន់តែស៊ីជម្រៅទៅទៀតនោះ ជីវិតជាលក្ខណៈបុគ្គលជាច្រើន កំពុងត្រូវបានធ្វើឱ្យប៉ះពាល់តាមរយៈការកេងប្រវ័ញ្ច និងការមិនយកចិត្តទុកដាក់ដូចជា អំពើពេស្យាចារដោយបង្ខំ ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ និងអំពើធ្វើឱ្យដក់ជាប់នូវភាពអាម៉ាស់នៃជនពិការដែលអំពើទាំងនេះមានភស្ដុតាងច្បាស់លាស់ ហើយដែលធ្វើឱ្យខូចកិត្យានុភាពរបស់កម្ពុជា។ នាយករដ្ឋមន្ត្រី នៅក្នុងការគ្រប់គ្រងរាជរដ្ឋាភិបាលរបស់ខ្លួន ហាក់ដូចជាយកចិត្តទុកដាក់ខ្ពស់ចំពោះបញ្ហាជនក្រីក្រ ប៉ុន្តែកិច្ចប្រឹងប្រែងរបស់គាត់ជារឿយៗ មានរយៈពេលខ្លី និងកម្រនឹងផ្លាស់ប្ដូរគោលនយោបាយ និងសកម្មភាពរបស់អាជ្ញាធរដែលមានកំហុសណាស់។ ទោះបីជាយ៉ាងណាក៏ដោយ គាត់ត្រូវតែទទួលបាននូវទំនុកចិត្តមួយជាឧទាហរណ៍ នៅក្នុងការព្យាយាមដោះស្រាយបញ្ហាចាប់យកដី។ គាត់បានប្រាប់អ្នកចូលរួមនៅឯសន្និសីទជាតិ ស្ដីពីការគ្រប់គ្រងធនធានធម្មជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រ នៅខែធ្នូ ២០០៥ ថា *"សូមបញ្ឈប់ការទន្ទ្រានយកដី និងព្រៃឈើ។ ខ្ញុំសូមប្រកាសដល់អ្នកទាំងឡាយណា ជាពិសេសចំពោះមន្ត្រីរាជការកំពុងបំពេញភារកិច្ចនេះ ដែលរំលោភច្បាប់ និងបានចាប់យកតំបន់ព្រៃឈើ និងទន្ទ្រានយកដីរបស់រដ្ឋ ធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយធ្វើឱ្យប៉ះពាល់ដល់ប្រជាជនក្រីក្រ ថាដល់ពេលវេលាដែលអ្នកត្រូវឈប់បន្តសកម្មភាពទាំងនេះទៀតហើយ។"*

៤. ស្ថាប័នថ្មីៗនានារបស់កម្ពុជា មិនទាន់បង្ហាញដោយខ្លួនឯងថា ជាអាជ្ញាធរមានសមត្ថភាព និងអព្យាក្រឹត ដែលការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងធ្វើសកម្មភាពពិនិត្យមើលតុល្យភាពអំណាច នៅក្នុងដំណើរការប្រជាធិបតេយ្យនៅឡើយ។ ការជាប់ពាក់ព័ន្ធរបស់គណបក្សនយោបាយ នៅតែមានលក្ខណៈច្បាស់លាស់។ រដ្ឋសភាមិនទាន់បញ្ចេញឥទ្ធិពលរបស់ខ្លួនលើអង្គនីតិប្រតិបត្តិ ចំពោះគោលនយោបាយ ឬបញ្ហាសំខាន់ៗនៅឡើយ ហើយត្រូវបានធ្វើឱ្យទន់ខ្សោយដោយការលាលែងពីតំណែងរបស់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជាប្រធានរដ្ឋសភា។ ព្រះអង្គម្ចាស់ ដែលតំណាងឱ្យគណបក្សសម្ព័ន្ធភាពសំឡេងតិច គឺជាបុគ្គលមានឋានៈខ្ពស់ ធ្លាប់ជាអតីតនាយករដ្ឋមន្ត្រី ហើយទោះបីជាមានភាពរកាំរកូសកើតឡើងចំពោះគណបក្សរបស់ព្រះអង្គនាពេលចុងក្រោយក៏ដោយ ព្រះអង្គបានបង្ហាញការតាំងចិត្តពិតប្រាកដមួយ ក្នុងការព្យាយាមធ្វើឱ្យរដ្ឋសភាមានដំណើរការ។ ទោះបីជាបានឈរឈ្មោះជាតំណាងសមាជិករដ្ឋសភានៅតែមិនបង្ហាញឱ្យបានច្បាស់ថា ពួកគេគឺជា

អ្នកតំណាងតាមមណ្ឌលរបស់ខ្លួនដែលលើកតំកើង និងការពារផលប្រយោជន៍របស់មណ្ឌល ជាជាងប្រយោជន៍របស់ថ្នាក់ដឹកនាំគណបក្សនយោបាយ (សូមមើលរបាយការណ៍សង្កេតសភារបស់ខុមហ្វ្រែល)។ ស្ថាប័នជាន់-ខ្ពស់នានា ដូចជា ក្រុមប្រឹក្សាធម្មនុញ្ញ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏មានភាពលម្អៀងយ៉ាងច្បាស់ចំពោះគណបក្សកាន់អំណាចដែរ។ ចំណែកស្ថាប័នផ្សេងទៀត ក៏មិនទាន់បង្ហាញអំពីជំហររបស់ខ្លួននៅឡើយ ដូចដែលបានពិពណ៌នានៅក្នុងផ្នែកផ្សេងៗនៃរបាយការណ៍នេះលម្អិត និងនៅក្នុងរបាយការណ៍ផ្លូវការផ្សេងទៀត ស្តីពីប្រទេសកម្ពុជា។

៥. ប្រទេសកម្ពុជានៅតែពឹងអាស្រ័យយ៉ាងខ្លាំងលើជំនួយហិរញ្ញវត្ថុពីខាងក្រៅ។ ការកសាងសមត្ថភាពផ្ទាល់របស់ខ្លួន ដើម្បីបង្កើនចំណូល និងប្រតិបត្តិការសេវាកម្ម ត្រូវការរយៈពេលយូរ។ ខណៈពេលដែលការរីកចម្រើន គួរឱ្យកត់សម្គាល់នូវដំណើរការសេដ្ឋកិច្ចបានល្អនៅពេលថ្មីៗនេះ ផលប្រយោជន៍បានកើនឡើងតិចតួចប៉ុណ្ណោះ ហើយត្រូវបានកម្រិតតែទៅលើវិស័យវាយនភ័ណ្ឌ និងទេសចរណ៍។ សកម្មភាពការងារមិនគ្រប់គ្រាន់ទេ ដើម្បីធ្វើអតិបរមាកម្មសក្តានុពលវិស័យកសិកម្ម និងជម្រើសនានាសម្រាប់ជីវិតរស់នៅចំពោះប្រជាពលរដ្ឋប្រមាណ៨៥% រស់នៅតាមតំបន់ជនបទ។ អំពើពុករលួយមានលក្ខណៈរាលដាល ដូចជា ការយកកម្រៃ និងពន្ធអាករក្រៅផ្លូវ-ការគ្រប់ទីកន្លែងទៅលើប្រជាពលរដ្ឋគ្រប់រូប ទោះបីជាជនក្រីក្របំផុត នៃមន្ត្រីដែលធ្វើការខ្ជីខ្ជានៅតាមស្ថាប័នសាធារណៈ។ បញ្ហានេះ នៅតែជាការបាត់បង់ចំណូលដ៏ធំរបស់រាជរដ្ឋាភិបាល ក៏ដូចជាការប្រើប្រាស់ទ្រព្យ-សម្បត្តិរដ្ឋមិនត្រឹមត្រូវយ៉ាងធ្ងន់ធ្ងរ។ រាជរដ្ឋាភិបាល នៅក្នុងការដោះស្រាយជាមួយនឹងក្រុមពិគ្រោះយោបល់ម្ចាស់ជំនួយកម្ពុជា បានប្តេជ្ញាចិត្តតាមគោលរង្វាស់ដើម្បីធ្វើការវាយតម្លៃការរីកចម្រើន ប៉ុន្តែមិនទាន់បានបង្ហាញលទ្ធផលជាក់ស្តែង និងមាននិរន្តរភាពនៅឡើយនៅក្នុងវិស័យភាគច្រើន ឬស្ទើរតែទាំងអស់។ បញ្ហា ដែលត្រូវបានកត់សម្គាល់បន្ថែមពីលើនេះទៀត រួមមាន ការប្រើប្រាស់មូលនិធិរបស់ម្ចាស់ជំនួយមិនត្រឹមត្រូវ ដោយមានការធ្វើលទ្ធកម្មមិនត្រឹមត្រូវត្រូវ បានកត់សម្គាល់ឃើញនៅក្នុងកម្មវិធីស្បៀងអាហារពិភពលោក និង គម្រោងជាច្រើនរបស់ធនាគារពិភពលោក(ថ្មីៗបំផុតចុងក្រោយនេះគឺនៅក្នុងខែឧសភា ឆ្នាំ២០០៦) ដែល ឈានទៅដល់ការផ្អាកគម្រោង និងឈប់ផ្តល់មូលនិធិ។ ចំពោះបាតុភាពទាំងនេះ មានហានិភ័យដែលថា ម្ចាស់ជំនួយអាចធុញទ្រាន់ ហើយធ្វើឱ្យបាត់បង់ចំណូលនាពេលអនាគត ប្រសិនបើមិនមានការខិតខំដើម្បីធ្វើឱ្យស្ថានភាពនេះល្អប្រសើរឡើងវិញទេនោះ។

**ខុមហ្វ្រែល** រក្សាការជំនឿទុកចិត្តពេញលេញមួយ ចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាសម្រាប់រយៈពេលដែលនៅសេសសល់នៃនីតិកាលទី ៣ នេះ ដើម្បីមានលទ្ធភាពអនុវត្តចំណុចសំខាន់ៗ នៅក្នុងកម្មវិធីនយោបាយ ជាពិសេសបណ្តា ចំណុចដែលត្រូវបានសន្យាសម្រេចឱ្យបាននៅមុនឆ្នាំ ២០០៥។ អាទិភាពទាំងនោះ រួមមាន :

១. ***ពង្រឹង និងជំរុញធម្មានុរូបភាព (ភាពត្រឹមត្រូវតាមច្បាប់) នៃបណ្តាស្ថាប័នអព្យាក្រឹតនានា :*** រាជរដ្ឋាភិបាលគួរកំណត់បទដ្ឋាន សម្រាប់ការបង្កើត ***ស្ថាប័នរដ្ឋាភិបាលអព្យាក្រឹត និងឯករាជ្យ*** រួមមាន ស្ថាប័នសំខាន់ៗ ដូចជា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃកងយោធពលខេមរភូមិន្ទកម្ពុជា និងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។ ការងារនេះមានគោលដៅ *ហាម* កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទរបស់រដ្ឋ រួមមាន កងយោធពលខេមរភូមិន្ទ ទាហាន និងនគរបាលជាតិ ***មិនឱ្យចូលជាសមាជិកគណបក្សនយោបាយ។ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមត្រូវតែចែងឱ្យច្បាស់ថា ចៅក្រមមិនអាចជាសមាជិកគណបក្សនយោបាយឡើយ។ រាជរដ្ឋាភិបាល គួរតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការគ្រប់ប្រភេទទាំងអស់ឱ្យបានច្រើនជាងបរិមាណដែលលើកឡើងនៅក្នុងការសន្យា ដើម្បីសម្រួលជីវភាពស្របទៅនឹងបរិបទទីផ្សារបច្ចុប្បន្ន និងដើម្បីធានាប្រសិទ្ធភាពនៃសេវាសាធារណៈ។***

២. ***បង្កើតស្ថាប័នឯករាជ្យថ្មីនានាដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ*** ជាពិសេសគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ និងសិទ្ធិមនុស្ស។ *គណៈកម្មាធិការមិនលម្អៀង ឯករាជ្យ និងដាច់ដោយឡែកត្រូវតែបង្កើតឡើង ដើម្បីរៀបចំ*

*សេចក្តីណែនាំ និងលក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការជ្រើសរើសបេក្ខជនសម្រាប់ស្ថាប័នធម្មនុញ្ញទាំងអស់នេះ។*

៣. ***អនុម័តច្បាប់ថ្មី ដែលលើកស្ទួយតម្លាភាព និងគណនេយ្យភាពកាន់តែទូលាយជាងមុន :*** ច្បាប់ទាំងនេះរួមមាន ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ដែលត្រូវតែស្របតាមបទដ្ឋានអង្គការសហប្រជាជាតិ ជាពិសេសគោល-ការណ៍ទី ១៥ ស្តីពីការប្រកាសទ្រព្យសម្បត្តិរបស់នាយករដ្ឋមន្ត្រី សមាជិកគណៈរដ្ឋមន្ត្រី អភិបាលខេត្ត-ក្រុង សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងមន្ត្រីជាប់ឆ្នោតទាំងឡាយ នៅមុនពេល នៅអំឡុងពេល និងក្រោយ អាណត្តិការងាររបស់ខ្លួន និងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គណបក្សនយោបាយ។ រាជរដ្ឋាភិបាល ត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួន ដូចមានចែងនៅក្នុងមាត្រា ៩៦ និង ៩៧ នៃរដ្ឋធម្មនុញ្ញ ដែលតម្រូវឱ្យនាយក រដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាលឆ្លើយតបឱ្យបានសកម្មជាមួយសមាជិកសភា។ ចំពោះច្បាប់ស្តីពីហិរញ្ញវត្ថុរបស់ គណបក្សនយោបាយ ប្រទេសកម្ពុជាក៏ដូចជាជាមួយប្រទេសប្រជាធិបតេយ្យផ្សេងទៀត គួរអនុម័តច្បាប់សម្រាប់ ***ការបង្ហាញជាសាធារណៈពេញលេញ និងបទបញ្ញត្តិស្តីពីការផ្តល់មូលនិធិ*** របស់គណបក្សនយោបាយ ដើម្បីធានា ភាពយុត្តិធម៌នៅក្នុងដំណើរការបោះឆ្នោត។

៤. ***អនុម័ត និងធ្វើវិសោធនកម្មច្បាប់សំរាប់គាំទ្រកំណែទម្រង់ច្បាប់ :*** ដែលរួមមាន លក្ខន្តិកៈរបស់ចៅក្រម ក្រម ព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃសារការីសាធារណៈ។ ក្រមព្រហ្មទណ្ឌក៏គួរដកបទព្រហ្មទណ្ឌចេញ ពីបទល្មើសបរិហារកេរ្តិ៍ ដូចដែលនាយករដ្ឋមន្ត្រីបានសន្យា។

៥. ***ពង្រឹងតួនាទីរបស់គណបក្សជំទាស់ និងសេរីភាពបញ្ចេញមតិ*** ដូចជាតាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ការអនុម័តស្តីពីបាតុកម្ម និងកូដកម្ម និងការអនុម័តច្បាប់ស្តីពីសមាជជាតិ។ សូមអបអរ សាទរចំពោះការប្រកាសរបស់សម្តេចនាយករដ្ឋមន្ត្រី ក្នុងការធ្វើវិសោធនកម្មច្បាប់ដើម្បីលុបចោលទោសព្រហ្ម ទណ្ឌពីបទល្មើសបរិហារកេរ្តិ៍។

៦. ***ធ្វើការប្តេជ្ញាចិត្តនៅក្នុងពេលវេលាកំណត់ឱ្យកាន់តែច្បាស់លាស់មួយ ដើម្បីបង្កើនប្រសិទ្ធភាព និងល្បឿនសំរាប់ ចំណែកច្រើនជាងមុននៃការចំណាយថវិកាជាតិ*** ដើម្បីចំណាយទៅលើវិស័យសំខាន់ៗ ដូចជាវិស័យអប់រំ និង សុខាភិបាលជាពិសេស ដើម្បីនាំមកនូវការធានាការអប់រំជាមូលដ្ឋានចំនួន៩ឆ្នាំជាអប្បបរមា ចំពោះកុមារគ្រប់ រូប និងការថែទាំសុខភាពដោយមិនគិតថ្លៃ នៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

៧. ***បង្កើនប្រសិទ្ធភាពនៃកំណែទម្រង់ការគ្រប់គ្រងដីធ្លី*** ដោយពិនិត្យមើលឡើងវិញនូវដីទំនេររបស់រដ្ឋ ឬដីរដ្ឋដែល ឯកជនកាន់កាប់ ដែលមិនអនុលោមតាមក្របខណ្ឌគតិយុត្តិ និងនីតិវិធីដែលមានជាធរមាន និងដោយពិនិត្យ មើលការបែងចែកដីធ្លីក្នុងក្របខណ្ឌ នៃសម្បទានដីសង្គមកិច្ច និងពិនិត្យមើលការបែងចែកកម្មសិទ្ធិដីធ្លីជា ពិសេសចំពោះប្រជាជនក្រីក្រ និងជនងាយរងគ្រោះ។ រាជរដ្ឋាភិបាល គួរធ្វើឱ្យកាន់តែប្រសើរឡើងនូវ តម្លាភាព និងការពិគ្រោះយោបល់ឱ្យបានសមស្រប ជាមួយសហគមន៍ដែលទទួលផលប៉ះពាល់ដោយសារការផ្តល់សម្បទាន ដីដល់ អ្នកអភិវឌ្ឍន៍នៃវិស័យឯកជន។

*បេសកកម្មទីពីររបស់ខុមហ្វ្រែល គឺដើម្បីជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងប្រកបដោយព័ត៌មានគ្រប់គ្រាន់ ដែលក្នុងនោះសាធារណជនទូទៅ* ***យល់បានយ៉ាងច្បាស់នូវដំណើរការប្រជាធិបតេយ្យ មិនត្រឹមតែនៅមុនការបោះឆ្នោតប៉ុណ្ណោះ ទេ ប៉ុន្តែថែមទាំងនៅក្រោយ និងចន្លោះពេលបោះឆ្នោតទៀតផង។*** *ដើម្បីសំរេចបេសកកម្មនេះ* ***ខុមហ្វ្រែល*** *រៀបចំវគ្គសិក្សាអប់រំ និងវេទិកាសាធារណៈដើម្បីជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមនៅក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសម្រេចចិត្ត។ ខុមហ្វ្រែលជំរុញឱ្យមានការតស៊ូមតិ និងការបញ្ចុះបញ្ចូលក្នុងន័យស្ថាបនា សម្រាប់កែទម្រង់ការបោះឆ្នោត ដែលបង្កើន គណនេយ្យភាពរបស់បណ្តាមន្ត្រីជាប់ឆ្នោត។ និងចុងក្រោយ ដោយផ្តល់ នូវការសង្កេត និងឃ្លាំមើល ដើម្បីអាចឱ្យមានការវាយ តម្លៃដោយមិនលម្អៀង និងជាក់លាក់ត្រឹមត្រូវទៅលើការវិវឌ្ឍ នៃការប្តេជ្ញាចិត្តនៅក្នុងកម្មវិធីនយោបាយ និងការអនុវត្តសកម្ម ភាពការងាររបស់មន្ត្រីជាប់ឆ្នោតនានា។*

# វិធីសាស្ត្រ

**ខុមហ្វ្រែល** បាននិងកំពុងសង្កេត និងសិក្សាលើវឌ្ឍនៈភាពចំពោះការបំពេញកិច្ចសន្យា និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលដែលមានចែងនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាល ទី៣នៃរដ្ឋសភា ។

ការសង្កេតនេះ ផ្ដោតសំខាន់ទៅលើសូចនាករសំរាប់វាស់វែង ដែលឆ្លុះបញ្ចាំងនូវការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។ **មានសូចនាករពីរប្រភេទគឺៈ**

**ទី១ លទ្ធផលមានសូចនាករច្បាស់លាស់:** គឺសំដៅទៅលើលទ្ធផលជាក់ស្ដែងនានាដែលអាចវាស់បាន ដូចជាការធ្វើសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ដោយមានពេលវេលា ឬ មានចំនួនកំណត់ច្បាស់លាស់ ឧទាហរណ៏ ដូចជា ការរៀបចំអនុម័តច្បាប់អ្វីមួយ ឬការបង្កើតស្ថាប័ន ឬកាត់បន្ថយ ឬការបង្កើនចំនួនសកម្មភាពដល់កំរិតណាមួយ ។

**ទី២ គឺលទ្ធផលមានសូចនាករជាគោលបំណង:** គឺសំដៅទៅលើការអនុវត្តការងាររបស់រាជរដ្ឋាភិបាលលើកំរិតនៃសូចនារជាគោលបំណង និងការប្ដេជ្ញាចិត្ត ដែលជាទូទៅមិនអាចបញ្ជាក់នូវបរិមាណបានឡើយ ។

ជាលទ្ធផល សូចនាករមួយចំនួន ក្នុងចំណោមសូចនាករទាំងពីរខាងលើនេះ ត្រូវបានវាយតម្លៃដោយយោង ទៅតាមមតិយោបល់របស់ប្រភពបន្ទាប់បន្សំ ។ មតិយោបល់ត្រូវបានប្រមូលតាមរយៈបទសម្ភាសន៏ ។ ព័ត៌មានបន្ទាប់ បន្សំដូចជារបាយការណ៏ប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល របាយការណ៏ សិក្សាស្រាវជ្រាវនានា ត្រូវបានប្រមូលមកពី ក្រសួងពាក់ព័ន្ធនានាភ្នាក់ងារអង្គការសហប្រជាជាតិស្ថាប័នអន្តរជាតិ(ដូចជាធនាគារពិភពលោក) អង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នស្រាវជ្រាវផ្សេងៗ ។ ពាក្យពេចន៏ប្រើសំរាប់វាយតម្លៃសូចនាករជាបរិមាណមានដូចជាៈ

- មិនទាន់បានបំពេញ/អនុវត្ត
- បានបំពេញតិចតួច / ខ្លះតែមិនទាន់បានពេញលេញ
- បានបំពេញ / អនុវត្តបានភាគច្រើន
- អនុវត្ត / បំពេញបានពេញលេញ

ពាក្យពេចន៏ប្រើសំរាប់វាយតម្លៃសូចនាករជាបរិមាណមានដូចជាៈ អាក្រក់ និងខ្លាំង- ខ្សោយ-មធ្យម / បង្គួរ-ល្អ ។

សូចនាករជាបរិមាណនៃចំណុចនិមួយៗ គឺត្រូវបានសរសេរដោយអក្សរ ***ក្រាស់ខ្មៅ និងទ្រេត*** ហើយការវាយតម្លៃការអនុវត្តន៏ និងរៀបរាប់នៅក្នុងការសន្និដ្ឋានតាមចំណុចនិមួយៗ ។ សូចនាករជាគុណភាពត្រូវបានរៀបរាប់តែនៅក្នុងសេចក្ដីសង្ខេបប៉ុណ្ណោះ ដោយសារតែការវាយតម្លៃច្រើនពឹងផ្អែកលើមតិយោបល់ ជាជាងឯកសារ ។

របាយការណ៏នេះត្រូវបានបែងចែកជាបីផ្នែកធំៗទៅតាមកម្មវិធីនយោបាយ គឺផ្នែកនយោបាយ ផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គមកិច្ច ដែលផ្នែកចុងក្រោយនេះរួមមាន អប់រំ ការងារ ស្ត្រី កុមារ និងវប្បធម៌ សរុបមាន៧៣ចំណុច ដូចមានសង្ខេបនៅក្នុងផ្នែកពាក់ព័ន្ធនិមួយៗ ។

## ១- វិស័យនយោបាយ

- នយោបាយក្នុងប្រទេស
  - ការពង្រឹងសន្តិភាព ការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស
  - ការគោរពសិទ្ធិមនុស្ស
  - សេរីភាពខាងសារព័ត៌មាន និងការបញ្ចេញមតិ
  - តួនាទីរបស់មតិប្រឆាំង
  - ការរួមចំណែករបស់សង្គមស៊ីវិល
  - ការគ្រប់គ្រងតាមច្បាប់
  - កំណែទម្រង់រដ្ឋបាលសាធារណៈ
  - កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ

- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការកាត់រំសាយកងទ័ព
- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- កំណែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កំណែទម្រង់ការគ្រប់គ្រង ដីធ្លី និងធនធានធម្មជាតិ
- នយោបាយការពារជាតិ និងសន្តិសុខ

• នយោបាយក្រៅប្រទេស

**២- វិស័យសេដ្ឋកិច្ច**

• គោលការណ៍ទូទៅនៃគោលនយោបាយសេដ្ឋកិច្ច
• ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
• គោលនយោបាយសេដ្ឋកិច្ចតាមផ្នែក
  - កសិកម្ម
  - ឧស្សាហកម្ម
  - ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត
  - ពាណិជ្ជកម្ម
  - ទេសចរណ៍

**៣- វិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងវប្បធម៌**

• អប់រំ យុវជន និងកីឡា
• សុខាភិបាល
• សង្គមកិច្ច និងការងារ
• ស្ត្រី និងកុមារ
• វប្បធម៌


សម្រាប់ព័ត៌មានលម្អិត សូមទាក់ទង :

| | | | |
|---|---|---|---|
| - | លោក **ធន សារាយ** | តំណាងទី១ខុមហ្វ្រែល | ទូរស័ព្ទ ០១៦ ៨៨ ០៥ ០៩ |
| - | លោក **សុក សំអឿន** | គណៈកម្មាធិការនាយកខុមហ្វ្រែល | ទូរស័ព្ទ ០១២ ៩០ ១១ ៩៩ |
| - | លោក **គល់ បញ្ញា** | នាយកប្រតិបត្តិខុមហ្វ្រែល | ទូរស័ព្ទ ០១២ ៩៤ ២០ ១៧ |

***សំរាប់របាយការណ៍លំអិតសូមទំនាក់ទំនងមក:***

ទីស្នាក់ការកណ្តាល **ខុមហ្វ្រែល** ផ្ទះលេខ ១៣៨ ផ្លូវ ១២២

សង្កាត់ ទឹកល្អក់ទី១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ: **០២៣ ៨៨៤ ១៥០** ទូរសារ: **០២៣ ៨៨៣ ៧៥០**

អ៊ីម៉ែល: **comfrel@online.com.kh** វេបសាយ: **www.comfrel.org**